ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម
# ផែនការយុទ្ធសាស្ត្រ
# ២០២៤ - ២០២៨



គាំពារ
សង្គម
កម្ពុជា
SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែកុម្ភៈ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម
# ផែនការយុទ្ធសាស្ត្រ
# ២០២៤ - ២០២៨



គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម

ខែកុម្ភៈ ឆ្នាំ២០២៤

# មាតិកា


បុព្វកថា......I
ខ្លឹមសារសង្ខេបប្រតិបត្តិ......III
បញ្ជីអក្សរកាត់......V

**ជំពូកទី ១៖ ទិដ្ឋភាពទូទៅ**

**១.១ សេចក្តីផ្តើម...... ១**
១.១.១ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥...... ១
១.១.២ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០១៦ - ២០២៥...... ១
១.១.៣ ការវិភាគស្ថានភាព៖ បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម......២
**១.២ អត្ថប្រយោជន៍នៃផែនការយុទ្ធសាស្ត្រ...... ៥**

**ជំពូកទី ២៖ យុទ្ធសាស្ត្របរិវត្តកម្មឌីជីថលគាំពារសង្គម**

**២.១ ចក្ខុវិស័យ, បេសកកម្ម, និងគុណតម្លៃ......៧**
**២.២ ទិដ្ឋភាពទូទៅនៃគោលដៅយុទ្ធសាស្ត្រ...... ៩**
**២.៣ សមាសធាតុនៃយុទ្ធសាស្ត្រ......១១**
២.៣.១ ការពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្ត ក្នុងប្រព័ន្ធគាំពារសង្គមឌីជីល......១១
២.៣.២ ការអភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូលនៃប្រព័ន្ធ គាំពារសង្គមឌីជីថល......១៤
២.៣.៣ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធព័ត៌មានវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល...... ១៧
២.៣.៤ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការសម្របសម្រួលភាគីពាក់ព័ន្ធ នៃកិច្ចខិតខំបរិវត្តកម្មឌីជីថល......២២

**ជំពូកទី ៣៖ ការអនុវត្តយុទ្ធសាស្ត្រ**

**៣.១ តួអង្គ និងតួនាទីសំខាន់ៗ...... ២៤**
**៣.២ ការតាមដាន និងវាយតម្លៃ...... ២៥**

**ឧបសម្ព័ន្ធ១៖** ម៉ាទ្រីសនៃគោលដៅយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាព...... ២៦
**ឧបសម្ព័ន្ធ២៖** សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម......៣០

# បុព្វកថា

ផ្អែកលើសមិទ្ធផល និងបទពិសោធក្នុងការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល ក្នុងរយៈពេល ២៥ឆ្នាំកន្លងមក និងការវាយតម្លៃសម្រាប់ ២៥ឆ្នាំខាងមុខ ពោលគឺរហូតដល់ឆ្នាំ២០៥០, រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បានចាត់ទុក **"ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង"** ជាអាទិភាពមួយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយផ្តោតជាពិសេសលើការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈប្រមូលផ្តុំ និងសង្គតិភាព ស្របតាមអភិក្រមនៃវដ្តជីវិត ឈរលើគោលការណ៍ **"មិនបោះបង់ពលរដ្ឋណាម្នាក់"** ជាមួយនឹងទស្សនវិស័យ និងគោលដៅដ៏ច្បាស់លាស់គឺជំរុញ **"កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាបន្នសង្គម"**។

ជាមួយនឹងទស្សនវិស័យនេះ, ប្រព័ន្ធគាំពារសង្គមដែលរឹងមាំ ដើរតួនាទីកាន់តែសំខាន់ក្នុងការចូលរួមរក្សាតុល្យភាព និងលំនឹងជីវភាពរបស់ពលរដ្ឋ ដោយអាចធានាបាននូវសន្តិសុខប្រាក់ចំណូល, កាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ, ភាពងាយរងគ្រោះ, និងវិសមភាព ឈានទៅធានាជវភាព នៃកំណើនសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុ ប្រកបដោយបរិយាបន្ន និងធន់នឹងវិបត្តិ។

ដើម្បីឆ្លើយតបនឹងគោលដៅប្រកបដោយមហិច្ឆតា និងប្រាកដនិយមនេះ, បរិវត្តកម្មឌីជីថលបាន និងកំពុងដើរតួនាទីជាមូលដ្ឋានគ្រឹះដ៏សំខាន់ និងរួមចំណែក ក្នុងការបង្កើនប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, និងតម្លាភាពក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។ បរិវត្តកម្មឌីជីថលនេះ ក៏ឆ្លើយតបផងដែរទៅនឹងអាទិភាពទី៥ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ពោលគឺ **"មនុស្ស, ផ្លូវ, ទឹក, ភ្លើង, និងបច្ចេកវិទ្យា"** ដោយផ្តោតជាពិសេសលើ **"បច្ចេកវិទ្យាឌីជីថល"** សម្រាប់ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤។

**ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ២០២៤-២០២៨** កំណត់នូវយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាព សម្រាប់ដំណើរការបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ឈានទៅកសាងប្រព័ន្ធគាំពារសង្គមឌីជីថលមួយដែលរស់រវើក និងមានភាពសុខដុម តាមរយៈការពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្ត, ការអភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូល, ការធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល, និងការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ។ គំនិតផ្តួចផ្តើម **គាំពារសង្គមឌីជីថលនៅកម្ពុជា** ដែលបានចាប់ផ្តើមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការកំណត់អត្តសញ្ញាណ និងបើកផ្តល់អត្ថប្រយោជន៍គាំពារសង្គមនានាដល់ពលរដ្ឋគោលដៅបានយ៉ាងទូលំទូលាយ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព និងបន្តធ្វើបរិវត្តកម្ម និងសុខដុមនីយកម្មស្របតាមផែនការយុទ្ធសាស្ត្រនេះ សំដៅរួមចំណែកក្នុងការធ្វើឱ្យកាន់តែប្រសើរនូវការអនុវត្តគោលនយោបាយជាតិគាំពារសង្គមប្រកបដោយបរិយាបន្ន, ជឿទុកចិត្ត, និងសុវត្ថិភាពខ្ពស់។ ជាមួយនឹងស្មារតីនេះ, រាជរដ្ឋាភិបាលក៏រំពឹងថា **"ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ២០២៤-២០២៨"** នេះ នឹងរួមចំណែកក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ផងដែរ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រោមការដឹកនាំរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ចំពោះការសម្រេចបាននូវការរៀបចំផែនការយុទ្ធសាស្ត្រ ដែលជាសមិទ្ធផលដ៏មានសារៈសំខាន់ថ្មីមួយទៀត សម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជា។ ទន្ទឹមនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្ម ប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ក៏ដូចជាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធចំពោះការចូលរួមយ៉ាងសកម្មជាបន្តបន្ទាប់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចជារូបរាងឡើង។

ថ្ងៃអង្គារ ១១ កើត ខែ អាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

**ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ២០២៤-២០២៨** ដែលរៀបចំដោយក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមមានគោលបំណងបង្កើនសមិទ្ធិលទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាអតិបរមា ដើម្បីសម្រេចបាននូវគោលបំណង ដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមដែលរួមចំណែកកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ, ភាពងាយរងគ្រោះ, និងវិសមភាព ក៏ដូចជាការអភិវឌ្ឍធនធានមនុស្ស និងជំរុញកំណើនសេដ្ឋកិច្ច។

ផែនការយុទ្ធសាស្ត្រនេះ ផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, និងការលើកកម្ពស់គុណភាព និងភាពទាន់ពេលនៃទិន្នន័យ សម្រាប់ការរៀបចំគោលនយោបាយដែលផ្អែកលើភស្តុតាង និងការវិភាគជាក់ស្តែង ក៏ដូចជាការបើកផ្តល់អត្ថប្រយោជន៍ដល់អ្នកទទួលផលឱ្យបានកាន់តែប្រសើរ។ គោលដៅចម្បងនៃឯកសារដ៏សំខាន់នេះ គឺដើម្បីផ្តល់ដំណោះស្រាយឌីជីថល ក្នុងការកាត់បន្ថយភាពបែកខ្ញែកនៃប្រព័ន្ធចុះបញ្ជី, បន្ថយបន្ទុកការងាររបស់ប្រតិបត្តិករ, ធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រងទិន្នន័យប្រកបដោយសុវត្ថិភាព, និងបង្កើនភាពងាយស្រួលសម្រាប់ប្រជាជនគោលដៅក្នុងការទទួលអត្ថប្រយោជន៍គាំពារសង្គម។

## ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមនេះមាន គោលដៅយុទ្ធសាស្ត្រចំនួន ៤ សំខាន់ៗ ដូចខាងក្រោម៖

### ១. ពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តក្នុងប្រព័ន្ធគាំពារសង្គមឌីជីថល

បង្កើត និងធ្វើឱ្យកាន់តែប្រសើរឡើងនូវការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាដែលមានលក្ខណៈជាក់លាក់ និងចាំបាច់សម្រាប់គាំទ្រប្រព័ន្ធគាំពារសង្គមឌីជីថល។

### ៣. ធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល កាន់តែល្អប្រសើរ

ធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋា-រចនាសម្ព័ន្ធឌីជីថលដែលមានស្រាប់កាន់តែមានភាពប្រសើរ ឆ្ពោះទៅបង្កើតប្រព័ន្ធ ICT ស្របតាមនិម្មាបនកម្មនៃការធ្វើសុខដុមនីយកម្មប្រព័ន្ធ ICT ជាប្រព័ន្ធគាំពារសង្គមឌីជីថលរួម។



### ២. អភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូលនៃប្រព័ន្ធគាំពារសង្គមឌីជីថល

លើកកម្ពស់សមត្ថភាពធនធានមនុស្ស ដើម្បីភាពគ្រប់គ្រាន់ក្នុងដំណើរការធ្វើបរិវត្តកម្មឌីជីថលនៃប្រព័ន្ធគាំពារសង្គមប្រកបដោយភាពពេញលេញ និងជោគជ័យ។

### ៤. ធ្វើឱ្យការសម្របសម្រួលភាគីពាក់ព័ន្ធ និងកិច្ចខិតខំក្នុងការធ្វើបរិវត្តកម្មឌីជីថល កាន់តែល្អប្រសើរ

ពង្រឹងការសម្របសម្រួលភាគីពាក់ព័ន្ធនានា និងកិច្ចសហប្រតិបត្តិការក្នុងការធ្វើបរិវត្តកម្មឌីជីថលសម្រាប់ប្រព័ន្ធគាំពារសង្គម ដែលរួមបញ្ចូលទាំងភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល, វិស័យឯកជន, អង្គការសង្គមស៊ីវិល, និងដៃគូអភិវឌ្ឍន៍ទាំងអស់។

ដោយក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំ រៀបចំ និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, បរិវត្តកម្មឌីជីថលនៃប្រព័ន្ធគាំពារសង្គម និងការអនុវត្តយុទ្ធសាស្ត្រនេះ ស្ថិតនៅក្រោមសមត្ថកិច្ចនៃការសម្របសម្រួល និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមផងដែរ។

ការតាមដាន និងវាយតម្លៃ នឹងធ្វើឡើងដើម្បីធានាបានថា វឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឌីជីថលទៅតាមផែនការយុទ្ធសាស្ត្រនេះ នឹងអនុវត្តស្របតាមតាមឧត្តមានុវត្តន៍នៃបច្ចេកវិទ្យាចុងក្រោយ។ ផែនការប្រតិបត្តិ នឹងរៀបរាប់លម្អិតអំពីសកម្មភាព, បង្គោលចរ, ក្របខណ្ឌពេល, តួអង្គទទួលបន្ទុកការងារ, និងលទ្ធផលចុងក្រោយទាំងអស់ ដែលនឹងត្រូវសម្រេចបាន។ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពនឹងត្រូវបានវាយតម្លៃជាប្រចាំ ដោយយន្តការស្ថាប័នដែលនឹងត្រូវបង្កើតឡើង។

ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមនឹងត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីទិសដៅយុទ្ធសាស្ត្រដែលមានកំណត់នៅក្នុង **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២.០**។

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល | Non-Governmental Organizations |
| **SPiC** | គាំពារសង្គមកម្ពុជា | Social Protection in Cambodia |
| **ICT** | បច្ចេកវិទ្យាព័ត៌មាន | Information and Communication Technology |
| **SPR** | មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម | Social Protection Registry |
| **DSPP** | ថ្នាលគាំពារសង្គមឌីជីថល | Digital Social Protection Platform |
| **IDPoor** | ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ | Identification of Poor Households |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា | Ministry of Education, Youth and Sport |
| **MoP** | ក្រសួងផែនការ | Ministry of Planning |
| **MoSAVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | Ministry of Social Affairs, Veterans and Youth Rehabilitation |
| **NSAF** | មូលនិធិជាតិជំនួយសង្គម | National Social Assistance Fund |
| **NSSF** | បេឡាជាតិសន្តិសុខសង្គម | National Social Security Fund |
| **NSPC** | ក្រុមប្រឹក្សាជាតិគាំពារសង្គម | National Social Protection Council |
| **NPCA** | ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ | National Payment Certification Agency |
| **PMRS** | ប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ | Patient Management and Registration System |
| **SFIS** | ប្រព័ន្ធព័ត៌មានអំពីការផ្តល់អាហារតាមសាលារៀន | School Feeding Information System |

# ជំពូកទី១

# និន្នាការទូទៅ



# ១.១

## សេចក្តីផ្តើម

បរិវត្តកម្មឌីជីថល ជាការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវដំណើរការ, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពនៃប្រព័ន្ធ និងបទពិសោធរួមរបស់អ្នកប្រើប្រាស់។ ក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា ពាក្យ "អ្នកប្រើប្រាស់" គឺសំដៅលើអត្ថគាហក ឬអ្នកទទួលផលពីកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម។

បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម អាចផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងប្រព័ន្ធទាំងមូល។ ឧទាហរណ៍៖ ដំណើរការនៃការបំពេញការងាររបស់ប្រតិបត្តិករ និងអ្នកចូលរួមពាក់ព័ន្ធទាំងអស់អាចត្រូវបានកាត់បន្ថយបន្ទុក ដោយការធ្វើស្វ័យប្រវត្តិកម្មតាមរយៈប្រព័ន្ធ ICT។ ជាងនេះទៀត, ថ្នាក់ដឹកនាំ និងអ្នកបង្កើតគោលនយោបាយនឹងទទួលបានអត្ថប្រយោជន៍ពីទិន្នន័យដែលអាចរកបានទាន់ពេល និងត្រឹមត្រូវ ខណៈដែលអត្ថគាហក ឬអ្នកទទួលផលនឹងទទួលបាននូវភាពងាយស្រួលបន្ថែមទៀតនៅពេលទៅទទួលសេវា និងបើកកញ្ចប់អត្ថប្រយោជន៍ផ្សេងៗពីប្រព័ន្ធគាំពារសង្គម។

### ១.១.១ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦ - ២០២៥

កិច្ចខិតខំអភិវឌ្ឍប្រព័ន្ធគាំពារសង្គមបច្ចុប្បន្នត្រូវបានធ្វើឡើងដោយអនុលោមទៅតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។ ក្របខណ្ឌគោលនយោបាយនេះបានបង្ហាញយ៉ាងច្បាស់អំពីវិស័យដែលត្រូវធ្វើការកែទម្រង់ ដើម្បីធានាសន្តិសុខប្រាក់ចំណូលរបស់ប្រជាជន, កាត់បន្ថយភាពក្រីក្រ, ពង្រឹងស្ថិរភាពហិរញ្ញវត្ថុ, និងនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមដែលផ្តោតលើប្រព័ន្ធជំនួយសង្គម និងសន្តិសុខសង្គម មានធាតុផ្សំជាច្រើន និងមានគោលដៅសំខាន់ៗមួយចំនួនដែលអាចទទួលបានអត្ថប្រយោជន៍ពីការធ្វើបរិវត្តកម្មឌីជីថល។ ជារួម ក្របខណ្ឌគោលនយោបាយបានបង្ហាញពីតម្រូវការក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព, តម្លាភាព, និងការសម្របសម្រួលភាគីពាក់ព័ន្ធនៃប្រព័ន្ធគាំពារសង្គម។ ប្រព័ន្ធកំណត់អត្តសញ្ញាណ និងចុះបញ្ជីក្រុមគោលដៅត្រូវធ្វើឌីជីថលូបនីយកម្ម និងសុខដុមនីយកម្ម ដើម្បីលុបបំបាត់ការចុះបញ្ជី និងផ្តល់កញ្ចប់អត្ថប្រយោជន៍ស្ទួន។ បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចគោលដៅនៃកិច្ចខិតខំកែទម្រង់ប្រព័ន្ធគាំពារសង្គមទាំងមូល។

### ១.១.២ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ក្នុងឆ្នាំ២០២១, រាជរដ្ឋាភិបាលបានដាក់ចេញក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលបានកំណត់នូវចក្ខុវិស័យកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលបែបរស់រវើក ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើមូលដ្ឋានគ្រឹះចំនួន ២ គឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និងការកសាងភាពជឿជាក់ និងទំនុកចិត្តលើប្រព័ន្ធឌីជីថល។ លើសពីនេះ ក្របខណ្ឌគោលនយោបាយនេះ មានសសរស្តម្ភចំនួន ៣ គឺការអភិវឌ្ឍពលរដ្ឋឌីជីថល, រដ្ឋាភិបាលឌីជីថល, និងការជំរុញធុរកិច្ចឌីជីថល។ វិធានការគោលនយោបាយផ្សេងៗ ត្រូវរៀបចំដោយឈរលើគោលគំនិតទាញយកប្រយោជន៍ពីសេដ្ឋកិច្ច និងសង្គមឌីជីថល ឱ្យបានជាអតិបរមា និងកាត់បន្ថយហានិភ័យ ឬផលជះអវិជ្ជមានឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

កិច្ចខិតខំក្នុងការធ្វើបរិវត្តកម្មឌីជីថលសម្រាប់ប្រព័ន្ធគាំពារសង្គមមានទិសដៅស្របតាមក្របខណ្ឌ តាមរយៈគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលខាងលើ។ការធ្វើទំនើបភាវូបនីយកម្មនៃប្រព័ន្ធគាំពារសង្គម

តាមរយៈការចាប់យកបច្ចេកវិទ្យា ICT រួមចំណែកក្នុងការសម្រេចនូវគោលដៅរបស់ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល និងជាពិសេសរួមចំណែកកសាងពលរដ្ឋ និងរដ្ឋាភិបាលឌីជីថលផងដែរ។

### ១.១.៣ ការវិភាគស្ថានភាពៈ បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម

យោងតាមក្របខណ្ឌទាំងនេះ, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បានដាក់ចេញនូវការសិក្សាស្ថានភាពមួយក្នុងឆ្នាំ២០២១។ តួអង្គសំខាន់ៗក្នុងប្រព័ន្ធគាំពារសង្គមត្រូវបានសម្ភាស ដើម្បីកំណត់អំពីស្ថានភាពបច្ចុប្បន្នដែលពាក់ព័ន្ធនឹងការធ្វើបរិវត្តកម្មឌីជីថល ដែលកំពុងកើតឡើងនៅក្នុងស្ថាប័ន ឬអង្គភាព។ សំណួរនៅក្នុងកិច្ចសម្ភាសន៍នោះដែលជាកម្មវត្ថុនៃការវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់ រួមមានៈ ប្រព័ន្ធឌីជីថលប្រភេទណាដែលត្រូវបានចាប់យកនាពេលបច្ចុប្បន្ន, បញ្ហាប្រឈមអ្វីខ្លះដែលបាន និងកំពុងជួបប្រទះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល, និងផែនការអភិវឌ្ឍន៍រយៈពេលវែងនៃស្ថាប័ន ឬអង្គភាព។ ដៃគូអភិវឌ្ឍន៍នានាដែលមានភាពសកម្មក្នុងប្រព័ន្ធគាំពារសង្គមក៏ត្រូវបានពិគ្រោះយោបល់ផងដែរ ដើម្បីកំណត់អំពីសកម្មភាព និងកិច្ចខិតខំរបស់ពួកគេក្នុងការជួយគាំទ្រប្រតិបត្តិករគាំពារសង្គមនានា។

### ការសិក្សានេះបានរកឃើញស្ថានភាពចម្បងៗ ដូចខាងក្រោមៈ

**កិច្ចខិតខំផ្នែកឌីជីថលូបនីយកម្មមានភាពទូលំទូលាយៈ** ដំណោះស្រាយឌីជីថលត្រូវបានចាប់យកមកប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រតិបត្តិករគាំពារសង្គមផ្សេងៗគ្នាដែលក្នុងនោះប្រព័ន្ធបច្ចេកវិទ្យាភាគច្រើនត្រូវបានអភិវឌ្ឍដោយក្រសួង ស្ថាប័នផ្ទាល់ ប៉ុន្តែខ្លះទៀតត្រូវបានចូលរួមអភិវឌ្ឍដោយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។ ស្របពេលជាមួយគ្នានេះ, ការគាំទ្រយ៉ាងទូលំទូលាយក្នុងបរិវត្តកម្មឌីជីថលពីតួអង្គក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជាបាន និងកំពុងមានការកើនឡើង នៅគ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់។ ជាងនេះទៀត, គ្រប់ប្រតិបត្តិករក្នុងប្រព័ន្ធគាំពារសង្គម មានក្រុមការងារបច្ចេកវិទ្យាព័ត៌មានរៀងៗខ្លួន តែពួកគេនៅតែមិនទាន់អាចចូលរួមចំណែកពេញលេញក្នុងការធ្វើបរិវត្តកម្មឌីជីថលជាយុទ្ធសាស្ត្រនៅឡើយ ដោយសារក្រុមការងារភាគច្រើនមានចំណេះដឹង និងប្រវត្តិការងារផ្នែកបច្ចេកវិទ្យា នៅមានកម្រិតនៅឡើយ។ ភាពចាស់ទុំនៃដំណើរការក្នុងការប្រើប្រាស់ប្រព័ន្ធ ICT មានភាពខុសប្លែកពីគ្នា ខណៈដែលតួអង្គគាំពារសង្គមណាមានភាពចាស់ទុំជាង តែងមានប្រព័ន្ធ ICT ដែលគាំទ្រដំណើរការការងារពីដើមដល់ចប់ (end-to-end)។

**អវត្តមាននៃទស្សនៈវិស័យ និងយុទ្ធសាស្ត្ររួមៈ** បច្ចុប្បន្ន, ក្រុមការងារបច្ចេកទេសកំពុងគិតគូរអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើប្រតិបត្តិការ និងធ្វើអន្តរកម្មជាមួយគ្នាបានសម្រាប់តួអង្គគាំពារសង្គមទាំងអស់ ខណៈដែលតួអង្គគាំពារសង្គមនីមួយៗ បាន និងកំពុងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីបម្រើ និងបំពេញតម្រូវការ តែការផ្តល់សេវាគាំពារសង្គមតាមចរិតលក្ខណៈនៃកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមរៀងៗខ្លួន។ ជាងនេះទៀត, ការអភិវឌ្ឍប្រព័ន្ធ ICT បានផ្តោតសំខាន់តែលើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធឌីជីថលកាន់តែមានភាពប្រសើរប៉ុណ្ណោះ ដោយមិនបានផ្តោតលើកត្តាសំខាន់ៗផ្សេងទៀត ដូចជាគោលនយោបាយ ICT និងការអភិវឌ្ឍធនធានមនុស្សនៅឡើយ។

**លទ្ធភាព និងសមត្ថភាពធនធានមនុស្សៈ** ធនធានមនុស្ស ជាកត្តាដ៏សំខាន់មួយ ដែលបង្កឱ្យមានបញ្ហាប្រឈមពាក់ព័ន្ធផ្សេងៗទៀត ដូចជាកង្វះសន្តិសុខសាយប័រនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលក្នុងទិដ្ឋភាពនេះ បញ្ហាប្រឈមត្រូវបានបែងចែកជា ២ ផ្នែកធំៗ ដូចខាងក្រោមៈ

១. ចំនួនមុខតំណែងសម្រាប់មន្ត្រីលើផ្នែកនេះ និងភាពមានកម្រិតនៃធនធាន និង
២. គុណវុឌ្ឍិ ក៏ដូចជាបទពិសោធរបស់មន្ត្រីទទួលបន្ទុក នៅមិនទាន់សមស្របទាំងស្រុងទៅនឹងលក្ខខណ្ឌការងារ។

ជាងនេះទៀត, អ្នកជំនាញ ICT មានតម្រូវការខ្ពស់នៅក្នុងទីផ្សារការងារ ខណៈដែលតួអង្គគាំពារសង្គម មិនអាចផ្តល់កញ្ចប់បៀវត្សរ៍ដែលមានលក្ខណៈប្រកួតប្រជែងនៅឡើយ បើធៀបនឹងវិស័យឯកជន ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការជ្រើសរើស និងរក្សាបុគ្គលិកសម្រាប់រយៈពេលវែង។

**ប្រព័ន្ធព័ត៌មានវិទ្យាភាគច្រើនកំពុងដំណើរការដាច់ដោយឡែកពីគ្នា (silos)៖** ទោះបីជាបច្ចុប្បន្នមានការតភ្ជាប់រវាងប្រព័ន្ធព័ត៌មានវិទ្យាមួយចំនួនក៏ដោយ តែអភិក្រមនៃការធ្វើសុខដុមនីយកម្ម និងអន្តរប្រតិបត្តិការនៅតែមានភាពកង្វះចន្លោះ។ តួយ៉ាង, ការតភ្ជាប់ដើម្បីធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធព័ត៌មានវិទ្យាមួយចំនួនត្រូវបានធ្វើឡើងទៅតាមករណីដែលភាគីនីមួយៗចង់បាន ដើម្បីតែបំពេញតម្រូវការរៀងៗខ្លួន ដែលនេះបណ្តាលឱ្យការគ្រប់គ្រងទិន្នន័យនៅមានភាពបែកខ្ញែក និងមិនទាន់អាចបម្រើ និងបំពេញឱ្យគ្នាទៅវិញទៅមកក្នុងកម្រិតប្រព័ន្ធអេកូឡូស៊ីរួមនៅឡើយ និងធ្វើឱ្យតម្លៃនៃការប្រើប្រាស់ទិន្នន័យក្នុងប្រព័ន្ធគាំពារសង្គមក៏មិនទាន់ឈានដល់កម្រិតពេញលេញផងដែរ។

**តម្រូវការចាំបាច់នូវគោលនយោបាយ, គោលការណ៍ណែនាំ, និងស្តង់ដាឌីជីថល៖** ការកំណត់ស្តង់ដា និងគោលនយោបាយនានា ពិតជាមានតម្រូវការខ្លាំងណាស់សម្រាប់បង្ហាញផ្លូវក្នុងការធ្វើសកម្មភាព និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT នៅក្នុងប្រព័ន្ធគាំពារសង្គម។ ក្រៅពីការកំណត់ស្តង់ដា និងគោលនយោបាយឌីជីថល,

## ភាពខ្លាំង

១. ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមរបស់រាជរដ្ឋាភិបាលដែលមានការចូលរួម ពីតំណាងមកពីក្រសួង-ស្ថាប័នសំខាន់ៗត្រូវបានបង្កើតឡើង និងអាចណែនាំបន្ថែមលើការអភិវឌ្ឍប្រធានបទនេះ

២. មានការធ្វើបរិវត្តកម្មឌីជីថលជាច្រើនដែលបាន និងកំពុងដំណើរការនៅក្នុងចំណោមតួអង្គគាំពារសង្គមនានា។ នេះបង្ហាញថាមានការយល់ដឹងអំពីអត្ថប្រយោជន៍នៃបរិវត្តកម្មឌីជីថល និងឆន្ទៈក្នុងការអនុវត្តការងារនេះ។ គួរកត់សម្គាល់ផងដែរថា, បទពិសោធ និងសមត្ថភាពនៃការធ្វើបរិវត្តកម្មឌីជីថលមានរួចជាស្រេច និងអាចអភិវឌ្ឍបន្ថែមបាន និង

៣. ដៃគូអភិវឌ្ឍន៍នានាបាន និងកំពុងគាំទ្រយ៉ាងសកម្មដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា និងមានបំណងចង់ពង្រីកការគាំទ្រផងដែរ ក្នុងដំណើរការធ្វើបរិវត្តកម្មឌីជីថល។ ការគាំទ្រនេះ នឹងនាំមកនូវធនធានដែលចាំបាច់ជាច្រើនបន្ថែមទៀត។

## ភាពខ្សោយ

១. ធនធានមនុស្សក្នុងប្រព័ន្ធគាំពារសង្គមឌីជីថល ជាទូទៅមានភាពខ្វះខាតទាំងបរិមាណ និងគុណភាព

២. ចំណុចខ្វះចន្លោះផ្នែកគោលនយោបាយគាំពារសង្គមឌីជីថល និងក្របខណ្ឌច្បាប់ដែលនាំឱ្យមានការរារាំងដល់ការអភិវឌ្ឍបន្ថែម

៣. ពុំទាន់មានការយកចិត្តទុកដាក់គ្រប់គ្រាន់លើសន្តិសុខសាយប័រ ដោយសារភាពស្មុគស្មាញខ្លាំងនៃផ្នែកនេះ

៤. ទិន្នន័យភាគច្រើនមានលក្ខណៈដាច់ដោយឡែកពីគ្នា (silos)។ ប្រព័ន្ធ ICT កំពុងដំណើរការដោយពុំបានប្រើប្រាស់ទិន្នន័យសម្រាប់ការធ្វើការសម្រេចចិត្ត។ ឧបសគ្គដែលនាំឱ្យមានបញ្ហានេះ គឺឆន្ទៈក្នុងការចែករំលែកទិន្នន័យក្នុងចំណោមភាគីពាក់ព័ន្ធ និងអន្តរប្រតិបត្តិការរវាងប្រព័ន្ធ ICT នានា

៥. កិច្ចខិតខំនៃបរិវត្តកម្មឌីជីថលនៅមិនទាន់មានទិដ្ឋភាពរួម សម្រាប់ប្រព័ន្ធទាំងមូល និងមិនទាន់មានភាពសុខដុមនៅឡើយ។ ភាគីពាក់ព័ន្ធនៃប្រព័ន្ធគាំពារសង្គម មិនទាន់មានឆន្ទៈគ្រប់គ្រាន់ក្នុងការគិតពីវិស័យទាំងមូល ដោយគិតគូរតែក្នុងក្របខណ្ឌការងារ និងតម្រូវការរៀងៗខ្លួន និង

៦. ប្រព័ន្ធ ICT ចាស់ៗមួយចំនួនត្រូវការធនធានយ៉ាងច្រើន ដើម្បីធ្វើទំនើបកម្ម។

ការកំណត់និយមន័យទិន្នន័យ, បច្ចេកវិទ្យាកុំព្យូទ័រ, អន្តរប្រតិបត្តិការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការគ្រប់គ្រងគម្រោង ICT, ការផ្តល់អាទិភាពនៃការវិនិយោគ, សន្តិសុខសាយប័រ, និងការការពារទិន្នន័យ ក៏គួរត្រូវការនូវការយកចិត្តទុកដាក់ផងដែរ ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នារវាងប្រតិបត្តិករនីមួយៗ។

ស្ថានភាពនៃបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ត្រូវបានពិពណ៌នាបន្ថែមទៀត តាមរយៈការវិភាគភាពខ្លាំង, ភាពខ្សោយ, កាលានុវត្តភាព, និងកត្តាគំរាមកំហែង (SWOT Analysis) ដូចមានលម្អិតក្នុងគំនូសបំព្រួញខាងក្រោម។

## ឱកាស

១. មានការគាំទ្រពីថ្នាក់ដឹកនាំចំពោះប្រធានបទនេះ, ដោយរាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការធ្វើបរិវត្តកម្មឌីជីថលដែលជាកត្តាជំរុញសម្រាប់ការអភិវឌ្ឍ

២. រាជរដ្ឋាភិបាលមានថ្នាលផ្លាស់ប្តូរទិន្នន័យផ្លូវការដែលមានភាពចាស់ទុំ ហៅថា CamDx

៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមជ្ឈមណ្ឌលទិន្នន័យដែលតួអង្គគាំពារសង្គមអាចមានលទ្ធភាពប្រតិបត្តិប្រព័ន្ធព័ត៌មានវិទ្យានានា និង

៤. ប្រព័ន្ធគាំពារសង្គមសម្រាប់ពលករចំណាកស្រុកពឹងផ្អែកលើការផ្លាស់ប្តូរទិន្នន័យឆ្លងប្រទេសដើម្បីធ្វើប្រតិបត្តិការ។ ការធ្វើទំនើបកម្មប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គមអាចរួមចំណែកឆ្ពោះទៅគោលដៅនៃការពង្រីកការគាំពារដល់ប្រជាជនចំណាកស្រុកផងដែរ។

## កត្តាគំរាមកំហែង

១. កិច្ចខិតខំនៃការធ្វើបរិវត្តកម្មឌីជីថលត្រូវការធនធានច្រើនហើយធនធានទាំងនោះទំនងជាមិនគ្រប់គ្រាន់សម្រាប់កិច្ចខិតខំនេះ នាពេលខាងមុខ

២. មានកង្វះខាតធនធានមនុស្សផ្នែកឌីជីថលនៅក្នុងប្រទេសកម្ពុជាខណៈដែលតួអង្គគាំពារសង្គមត្រូវធ្វើការប្រកួតប្រជែងជាមួយវិស័យឯកជន ដើម្បីទាក់ទាញធនធានមនុស្ស

៣. ហានិភ័យសន្តិសុខសាយប័រកើនឡើង ដោយសារមានកំណើន នៃការធ្វើឌីជីថលូបនីយកម្មក្នុងប្រព័ន្ធគាំពារសង្គម

៤. បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ត្រូវការជាចាំបាច់នូវការប្តេជ្ញាចិត្តពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងរយៈពេលវែង ប៉ុន្តែតួអង្គមួយចំនួនមានការងារអាទិភាពបន្ទាន់ផ្សេងទៀតដែលត្រូវបំពេញផងដែរ

៥. នៅមានកង្វះខាតនៃការយល់ដឹងលើប្រធានបទបរិវត្តកម្មឌីជីថល និងឱកាសដែលប្រធានបទនេះអាចបង្កើត

៦. អក្ខរកម្មឌីជីថលរបស់ប្រជាជនកម្ពុជា នៅមានកម្រិតនៅឡើយ (ការបែងចែកដាច់រវាងជនបទ-ទីក្រុង និងក្មេង-ចាស់) ដែលបណ្តាលឱ្យការពិភាក្សា និងការផ្តោតលើឯកជនភាពទិន្នន័យនៅមានកម្រិត និង

៧. នៅមានភាពខ្វះចន្លោះនូវបរិស្ថានឌីជីថលអំណោយផល ដូចជាអត្តសញ្ញាណឌីជីថល, ប្រព័ន្ធបើកផ្តល់ប្រាក់ពីរាជរដ្ឋាភិបាលទៅប្រជាជន, ការប្រើប្រាស់ភាសាខ្មែរសម្រាប់ប្រតិបត្តិការដែលរារាំងដល់លទ្ធភាពនៃការប្រើប្រាស់បញ្ញាសិប្បនិមិត្ត (AI), និងបទប្បញ្ញត្តិមួយចំនួន ដូចជាហត្ថលេខាឌីជីថលនិងការផ្ទុកទិន្នន័យស្តង់ដា។

# ១.២

## អត្ថប្រយោជន៍ នៃផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម មានគោលបំណងបង្កើនអត្ថប្រយោជន៍សម្រាប់ភាគីពាក់ព័ន្ធ៣ប្រភេទ គឺអត្ថគាហក ឬអ្នកទទួលផលនៃប្រព័ន្ធគាំពារសង្គម, ប្រតិបត្តិករនៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម, និងអ្នករៀបចំគោលនយោបាយ។

| | |
|---|---|
| **អត្ថប្រយោជន៍សម្រាប់ អត្ថគាហក ឬ អ្នកទទួលផល** | *ការឆ្លើយតបភ្ជាប់កម្មដោយតម្លាភាពនៃអត្ថគាហក ឬអ្នកទទួលផល* - លេខសម្គាល់អត្តសញ្ញាណ (SPID) មួយអាចប្រើប្រាស់សម្រាប់កម្មវិធី ឬរបបគាំពារសង្គមច្រើន |
| | *ការលុបបំបាត់ការងារស្ទួន* - ចៀសវាងនូវរាល់ការចុះបញ្ជី និងប្រមូលទិន្នន័យអត្តសញ្ញាណច្រើនដងសម្រាប់កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ |
| | *ការអនុម័ត និងការផ្ទេរពាក្យស្នើសុំលឿនជាងមុន* - អ្នកផ្តល់សេវាគាំពារសង្គមអាចពន្លឿនការអនុម័ត និងផ្ទេរកញ្ចប់អត្ថប្រយោជន៍ទៅអត្ថគាហក ឬអ្នកទទួលផល |
| | *បទពិសោធអ្នកប្រើប្រាស់កាន់តែប្រសើរ* - តាមរយៈដំណើរការប្រកបដោយភាពត្រឹមត្រូវ, ងាយស្រួល, និងតម្លាភាព |
| | *បង្កើនលទ្ធភាពនៃការខិតទៅកាន់តែជិតប្រជាជនគោលដៅ* - បង្កើនការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម តាមរយៈយន្តការចុះបញ្ជី និងកំណត់អត្តសញ្ញាណប្រសើរជាងមុនសម្រាប់អត្ថគាហក ឬអ្នកទទួលផល |
| | *ដំណោះស្រាយលឿនជាងមុន* -ផ្តល់មតិត្រឡប់, ធ្វើការតវ៉ា និងបណ្តឹង តាមរយៈប្រព័ន្ធឌីជីថល។ |

| | |
|---|---|
| **អត្ថប្រយោជន៍សម្រាប់ ប្រតិបត្តិករ** | *ការលុបបំបាត់ការងារស្ទួន* - ការចុះបញ្ជីក្នុងកម្មវិធី ឬរបបច្រើនតាមរយៈថ្នាលចុះបញ្ជីរួម |
| | *ការធ្វើឱ្យមានបរិយាបន្នជាអតិបរមា* - ការកំណត់អត្តសញ្ញាណអត្ថគាហក ឬអ្នកទទួលផលពីទិន្នន័យដែលមានស្រាប់នៅក្នុងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម |
| | *ព័ត៌មានដែលមានសុពលភាព* - ការផ្ទៀងផ្ទាត់ព័ត៌មាននៃអត្ថគាហក ឬអ្នកទទួលផលបានកាន់តែលឿនជាងមុន ដែលនឹងនាំទៅដល់ការកាត់បន្ថយការក្លែងបន្លំ ការប្រើប្រាស់លើសកំណត់ ឬការបើកផ្តល់កញ្ចប់អត្ថប្រយោជន៍ស្ទួន |
| | *ការពង្រឹងប្រព័ន្ធដែលមានស្រាប់បច្ចុប្បន្ន* - ការប្រើប្រាស់ម៉ូឌុលដែលចាំបាច់ ដោយកាត់បន្ថយ ចំណាយ និងកិច្ចខិតខំអភិវឌ្ឍបន្ថែម |
| | *ការផ្តល់អត្ថប្រយោជន៍គាំពារសង្គមប្រកបដោយប្រសិទ្ធភាព* - ការធ្វើស្វ័យប្រវត្តិកម្មសម្រាប់ការកំណត់អត្តសញ្ញាណអត្ថគាហក ឬអ្នកទទួលផល, ការចុះបញ្ជី, ការអនុម័ត, និងការផ្ទេរកញ្ចប់អត្ថប្រយោជន៍ |
| | *ប្រព័ន្ធដោះស្រាយបណ្តឹងតវ៉ាជាក់លាក់* - ធ្វើស្វ័យប្រវត្តិកម្មនៃនីតិវិធី។ |

**អត្ថប្រយោជន៍សម្រាប់អ្នករៀបចំគោលនយោបាយ**

***អាចមើលឃើញពីទិដ្ឋភាពរួម*** - សម្រាប់អត្ថគាហក ឬអ្នកទទួលផលទាំងអស់, អ្នកដែលអាចនឹងទទួលផលនាពេលអនាគត, និងអត្ថប្រយោជន៍នានាដែលទទួលបានពីរបបសន្តិសុខសង្គមផ្សេងៗ

***ការធ្វើឱ្យមានបរិយាប័ន្នជាអតិបរមា*** - តាមរយៈការកំណត់អត្តសញ្ញាណប្រជាជនគោលដៅ, អត្ថគាហក ឬអ្នកទទួលផល, ការសម្រេចចិត្តក្នុងការបង្កើតគោលនយោបាយឈានទៅការគ្របដណ្តប់ជាសកលនៃប្រព័ន្ធគាំពារសង្គម

***ការអនុវត្ត និងតាមដានប្រកបដោយប្រសិទ្ធភាព*** - អត្ថប្រយោជន៍ តាមរយៈការតាមដានគម្រោងនានាដែលអាចប្រើបានដោយមនុស្សគ្រប់គ្នា

***ទិន្នន័យ និងការវិភាគ*** - អនុញ្ញាតឱ្យធ្វើការសម្រេចចិត្ត និងបង្កើតជម្រើសគោលនយោបាយផ្អែកលើទិន្នន័យ

***ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងប្រព័ន្ធ ICT*** - ប្រតិបត្តិករគាំពារសង្គមនានា អាចប្រើប្រាស់មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គមដែលមានស្រាប់ ដើម្បីចាប់ផ្តើមប្រតិបត្តិការនៃកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមថ្មីៗដែលអាចជួយកាត់បន្ថយការចំណាយពេល និងចំណាយថវិកាក្នុងការអនុវត្ត

***បង្កើនការធ្វើសុខដុមនីយកម្ម*** - ការធ្វើសុខដុមនីយកម្មគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដោយកាត់បន្ថយជាអតិបរមានៃការក្លែងបន្លំ, ការបែកខ្ញែកនៃទិន្នន័យ, និងការគ្រប់គ្រង ។

# ជំពូកទី២

# យុទ្ធសាស្ត្រ
# បរិវត្តកម្មឌីជីថល
# គាំពារសង្គម



# ២.១

## ចក្ខុវិស័យ, បេសកកម្ម, និងគុណតម្លៃ

ចក្ខុវិស័យ, បេសកកម្ម, និងគុណតម្លៃនៃឯកសារផែនការយុទ្ធសាស្ត្រនេះ ស្របតាមក្របខណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិជាធរមានដែលរួមមាន៖

**ក្របខណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិសំខាន់ៗរួមមាន៖**

- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥;
- អនុក្រឹត្យ ស្តីពីការផ្លាស់ប្តូរទិន្នន័យកម្ពុជា;
- អនុក្រឹត្យ ស្តីពីហត្ថលេខាឌីជីថល;
- អនុក្រឹត្យ ស្តីពីការប្រើប្រាស់ ការគ្រប់គ្រង និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល;
- ផែនទីមគ្គុទ្ទេសក៍បច្ចេកវិទ្យាសុខាភិបាល ឆ្នាំ២០២២; និង
- សេចក្តីព្រាងយុទ្ធសាស្ត្រសុខាភិបាលឌីជីថល ឆ្នាំ២០២២។
- ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦- ២០២៥
- អនុក្រឹត្យ ស្តីពីការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម

## ចក្ខុវិស័យ

ពង្រីកវិសាលភាពនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាអតិបរមា ឆ្ពោះទៅការធ្វើឌីជីថលូបនីយកម្ម និងសុខដុមនីយកម្មប្រព័ន្ធគាំពារសង្គមក្នុងក្របខណ្ឌគាំពារសង្គមឌីជីថលពេញលេញ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ, ភាពងាយរងគ្រោះ, វិសមភាព, បរិយាបន្នសង្គម, ការអភិវឌ្ឍធនធានមនុស្ស, និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។



# បេសកកម្ម



ធ្វើឱ្យកាន់តែប្រសើរនូវគុណភាព និងភាពទាន់ពេលនៃទិន្នន័យដែលថ្នាក់ដឹកនាំ និងអ្នកបង្កើតគោលនយោបាយអាចធ្វើការសម្រេចបានដោយផ្អែកលើភស្តុតាងទិន្នន័យជាក់ស្តែង (Evidence-based);

បង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងប្រព័ន្ធគាំពារសង្គម។

ធ្វើឱ្យកាន់តែប្រសើរនូវការសម្របសម្រួល និងទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ និងសកម្មភាពសម្រាប់ការធ្វើបរិវត្តកម្មឌីជីថលគាំពារសង្គម; និង

ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី, គ្រប់គ្រងទិន្នន័យគាំពារសង្គម, និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ឆ្ពោះទៅធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធ ICT ជាប្រព័ន្ធអេកូឡូស៊ីគាំពារសង្គមរួម។

# គុណតម្លៃ

- បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ពឹងផ្អែកលើកិច្ចសហការយ៉ាងសកម្មរវាងភាគីពាក់ព័ន្ធទាំងអស់;
- វិធីសាស្ត្រក្នុងការធ្វើបរិវត្តកម្មឌីជីថល ត្រូវប្រកាន់ខ្ជាប់នូវ គោលការណ៍សម្រាប់ការអភិវឌ្ឍឌីជីថល ដែលជាការប្រមូលផ្តុំបទពិសោធរបស់អ្នកអនុវត្តការអភិវឌ្ឍឌីជីថល;
- គោលបំណងចម្បងនៃដំណោះស្រាយឌីជីថល គឺដើម្បីកាត់បន្ថយបន្ទុកការងាររបស់ប្រតិបត្តិករទាំងអស់ និងធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រង និងភាពត្រឹមត្រូវនៃទិន្នន័យ រួមទាំងបង្កើនភាពងាយស្រួលដល់ប្រជាជនគោលដៅដែលទទួលអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម;

- ដំណោះស្រាយឌីជីថលដែលបានចាប់យក គឺអាចអនុវត្តបានចំពោះបរិបទកម្ពុជា (ស្របតាមលក្ខខណ្ឌក្នុងស្រុក និងមានប្រសិទ្ធភាពខ្ពស់ផ្នែកចំណាយ);
- ដំណោះស្រាយឌីជីថល ផ្តោតលើសន្តិសុខសាយប័រ និងការការពារទិន្នន័យ; និង
- មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម នឹងបម្រើជាកន្លែងផ្ទុកនូវទិន្នន័យពិតរួមតែមួយសម្រាប់ប្រតិបត្តិករពាក់ព័ន្ធទាំងអស់ក្នុងប្រព័ន្ធគាំពារសង្គម ដោយគោរពតាមគោលការណ៍តែម្តងគត់ (Once-Only Principle) ដែលជាគោលការណ៍ដែលប្រជាជន ឬអាជីវកម្មអាចត្រូវផ្តល់ទិន្នន័យតែម្តងដល់រដ្ឋបាលនានា។ ការណ៍នេះ នឹងអនុញ្ញាតឱ្យមានការកំណត់អត្តសញ្ញាណប្រកបដោយតម្លាភាពនៅគ្រប់ប្រតិបត្តិករគាំពារសង្គម ខណៈពេលដែលឯកជនភាពទិន្នន័យត្រូវបានធានា។




# ២.២

## ទិដ្ឋភាពទូទៅនៃគោលដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មដែលបានកំណត់, ឯកសារផែនការ យុទ្ធសាស្ត្រនេះ នឹងដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ៤ ដូចខាងក្រោម៖



### គោលដៅទី១៖ ពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តក្នុងប្រព័ន្ធគាំពារសង្គមឌីជីថល

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រទី១នេះ សកម្មភាពអាទិភាពចំនួន៥ ត្រូវបានកំណត់ដូចខាងក្រោម៖

- សកម្មភាពអាទិភាពទី១ អភិវឌ្ឍគោលនយោបាយ ស្តីពីការចុះបញ្ជី និងការកំណត់អត្តសញ្ញាណតែមួយគត់សម្រាប់ប្រព័ន្ធគាំពារសង្គម
- សកម្មភាពអាទិភាពទី២ អភិវឌ្ឍគោលនយោបាយ ស្តីពីស្តង់ដា, ដំណើរការ, និងការផ្លាស់ប្តូរទិន្នន័យរវាងតួអង្គគាំពារសង្គម
- សកម្មភាពអាទិភាពទី៣ អភិវឌ្ឍគោលនយោបាយ ស្តីពីការការពារទិន្នន័យ និងសន្តិសុខសាយប័រ
- សកម្មភាពអាទិភាពទី៤ អភិវឌ្ឍគោលនយោបាយ ស្តីពីនិម្មាបនកម្ម, ហេដ្ឋារចនាសម្ព័ន្ធ, បណ្តុំបច្ចេកវិទ្យា, និងការផ្ទុក/ការរក្សាទុកទិន្នន័យនៃប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គម និង
- សកម្មភាពអាទិភាពទី៥ អភិវឌ្ឍក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ។



## គោលដៅយុទ្ធសាស្ត្រទី២៖ អភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូលនៃប្រព័ន្ធគាំពារសង្គមឌីជីថល

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រទី២នេះ សកម្មភាពអាទិភាពចំនួន៣ ត្រូវបានកំណត់ ដូចខាងក្រោម៖

- សកម្មភាពអាទិភាពទី១ ធ្វើការវិភាគចំណុចខ្វះចន្លោះនៃសមត្ថភាពធនធានមនុស្ស
- សកម្មភាពអាទិភាពទី២ រៀបចំផែនការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និង
- សកម្មភាពអាទិភាពទី៣ បង្កើនសមត្ថភាពប្រជាជនគោលដៅក្នុងការប្រើប្រាស់ឧបករណ៍ និងសេវាកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា។



## គោលដៅយុទ្ធសាស្ត្រទី៣៖ ធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធព័ត៌មានវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រទី៣នេះ សកម្មភាពអាទិភាពចំនួន៤ ត្រូវបានកំណត់ ដូចខាងក្រោម៖

- សកម្មភាពអាទិភាពទី១ ធ្វើការវិភាគភាពខ្វះចន្លោះ និងកំណត់អាទិភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- សកម្មភាពអាទិភាពទី២ អភិវឌ្ឍផែនការវិនិយោគសម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT
- សកម្មភាពអាទិភាពទី៣ អភិវឌ្ឍផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT និង
- សកម្មភាពអាទិភាពទី៤ ការកែលម្អការចុះបញ្ជីក្នុងកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមនានា។



## គោលដៅយុទ្ធសាស្ត្រទី៤៖ ធ្វើឱ្យកាន់តែប្រសើរឡើងនូវការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ នៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើបរិវត្តកម្មឌីជីថល

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រទី៤នេះ សកម្មភាពអាទិភាពចំនួន២ ត្រូវបានកំណត់ ដូចខាងក្រោម៖

- សកម្មភាពអាទិភាពទី១ អភិវឌ្ឍយន្តការប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងតួអង្គគាំពារសង្គម និង
- សកម្មភាពអាទិភាពទី២ អភិវឌ្ឍថ្នាលផ្លាស់ប្តូរព័ត៌មានក្រៅផ្លូវការ សម្រាប់អ្នកអនុវត្តប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គមទាំងអស់

គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពដែលបានកំណត់ នឹងត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិ, គោលនយោបាយ, និងគោលការណ៍ណែនាំពាក់ព័ន្ធដែលដាក់ចេញដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

# ២.៣

# សមាសធាតុនៃយុទ្ធសាស្ត្រ

## ២.៣.១. ការពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តក្នុងប្រព័ន្ធគាំពារសង្គមឌីជីថល

ការវាយតម្លៃស្ថានភាពបានបង្ហាញពីតម្រូវការនៃការធ្វើឱ្យកាន់តែប្រសើរឡើងនូវគោលនយោបាយ និងក្របខណ្ឌគតិយុត្តសម្រាប់ប្រព័ន្ធគាំពារសង្គមឌីជីថលក្នុងទិដ្ឋភាពរួម។ ចំណុចខ្វះចន្លោះដែលបាន និងកំពុងមាននៅពេលបច្ចុប្បន្ននេះ បានរារាំងដល់ការធ្វើបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ដោយសារមិនមានគោលនយោបាយ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងទិដ្ឋភាពឌីជីថលច្បាស់លាស់, តួអង្គគាំពារសង្គមនានាបានអភិវឌ្ឍប្រព័ន្ធ ICT របស់ពួកគេ តាមវិធីផ្សេងៗគ្នា ដែលធ្វើឱ្យការធ្វើសុខដុមនីយកម្ម និងអន្តរប្រតិបត្តិការរវាងប្រព័ន្ធទាំងអស់កាន់តែមានការលំបាក។ ដោយគ្មានបទដ្ឋានស្តង់ដាអប្បបរមា មុខងារសំខាន់ៗមួយចំនួននៃប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គម រួមមានសន្តិសុខសាយប័រ និងការការពារទិន្នន័យនៅមានភាពខ្វះខាតច្រើន ឬអវត្តមានតែម្តង។

គោលដៅយុទ្ធសាស្ត្រទី១ នេះ នឹងពង្រឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តដែលមានលក្ខណៈជាក់លាក់សម្រាប់ប្រព័ន្ធគាំពារសង្គមឌីជីថលទាំងមូល។ គោលដៅយុទ្ធសាស្ត្រនេះ នឹងប្រកាន់ខ្ជាប់ និងអនុលោមតាមគោលនយោបាយ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលមានលក្ខណៈទូទៅ និងមានគោលបំណងបម្រើដល់សង្គមជាតិទាំងមូល ជាជាងសម្រាប់តែវិស័យជាក់លាក់ណាមួយ។

### សកម្មភាពអាទិភាពទី១៖ អភិវឌ្ឍគោលនយោបាយ ស្តីពីការចុះបញ្ជី និងការកំណត់អត្តសញ្ញាណតែមួយគត់សម្រាប់ប្រព័ន្ធគាំពារសង្គម

សមត្ថភាពក្នុងការចុះបញ្ជី, កំណត់អត្តសញ្ញាណបុគ្គលម្នាក់ៗ, និងការពារការក្លែងបន្លំ ជាកត្តាសំខាន់បំផុតនៅក្នុងប្រព័ន្ធគាំពារសង្គម។ កញ្ចប់អត្ថប្រយោជន៍ដែលបានបើកផ្តល់ត្រូវតែបានទៅដល់ប្រជាជនគោលដៅដែលមានសិទ្ធិក្នុងការទទួល។ ករណីប្រព័ន្ធមិនមានវិធីដើម្បីកំណត់អត្តសញ្ញាណបុគ្គលម្នាក់ៗឱ្យមានប្រសិទ្ធភាព និងតម្លាភាពទេ, បុគ្គលម្នាក់អាចក្លែងខ្លួនជាបុគ្គលម្នាក់ផ្សេងទៀត ឬជាច្រើននាក់ ដើម្បីទទួលបានកញ្ចប់អត្ថប្រយោជន៍ពីការបើកផ្តល់ដោយប្រព័ន្ធគាំពារសង្គម។ ករណីបញ្ហានេះរីករាលដាល, ស្ថិរភាពហិរញ្ញវត្ថុនៃប្រព័ន្ធនឹងទទួលរងការគំរាមកំហែង និងធ្វើឱ្យមានការបាត់បង់ទំនុកចិត្តលើប្រព័ន្ធទាំងមូល។ ការកំណត់អត្តសញ្ញាណបុគ្គលនេះ កាន់តែមានសារៈសំខាន់នៅក្នុងរបបសន្តិសុខសង្គមផ្សេងៗដូចជាផ្នែកថែទាំសុខភាព, ហានិភ័យការងារ និងសោធនជាដើម ដោយសារមានកញ្ចប់អត្ថប្រយោជន៍ច្រើន និង/ឬពាក់ព័ន្ធនឹងភាគទាន ដែលបាន និងកំពុងបង់ដោយសមាជិកក្នុងរយៈពេលវែងជូនប្រតិបត្តិករ។

បច្ចុប្បន្ននេះ, ប្រតិបត្តិករគាំពារសង្គមផ្សេងៗគ្នា បានចាប់យកវិធីសាស្ត្រខុសៗគ្នា ដើម្បីកំណត់អត្តសញ្ញាណសមាជិក, អត្ថគាហក, ឬប្រជាជនគោលដៅ។ ខណៈដែលប្រតិបត្តិករទាំងអស់ចាប់យកការកំណត់អត្តសញ្ញាណបុគ្គលនីមួយៗ តាមរយៈលេខអត្តសញ្ញាណបណ្ណ, តួអង្គគាំពារសង្គមភាគច្រើនទៀតបានចេញលេខកូដសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួនថ្មីមួយទៀត សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធ ICT របស់ខ្លួន។ ខ្លះទៀត បានចេញបណ្ណជូនពលរដ្ឋ ដូចជាបណ្ណសមាជិក NSSF ឬបណ្ណសមធម៌ជាដើម។ បណ្ណខ្លះមានរូបថត ខណៈបណ្ណខ្លះទៀតមាន QR កូដ ហើយខ្លះទៀតក៏ប្រើប្រាស់បច្ចេកវិទ្យាសម្គាល់មុខផងដែរ។

ស្ថានភាពនេះ បានបង្ហាញយ៉ាងច្បាស់ថា អភិក្រមសម្រាប់កំណត់អត្តសញ្ញាណមិនទាន់មានសង្គតិភាពនៅឡើយ។

ជាគោលបំណងរួមនៃសកម្មភាពអាទិភាពនេះ ដើម្បីឆ្ពោះទៅអភិវឌ្ឍគោលនយោបាយសម្រាប់ប្រព័ន្ធគាំពារសង្គមទាំងមូលលើបញ្ហានេះដែលនឹងអនុញ្ញាតឱ្យមានការពង្រឹង និងធ្វើឱ្យមានសុខដុមនីយកម្មនៃអភិក្រមទាំងអស់ក្នុងការកំណត់អត្តសញ្ញាណ។

## សកម្មភាពអាទិភាពទី២៖ អភិវឌ្ឍគោលនយោបាយ ស្ដីពីស្ដង់ដា, ដំណើរការ, និង ការផ្លាស់ប្ដូរទិន្នន័យរវាងតួអង្គគាំពារសង្គម

ប្រព័ន្ធគាំពារសង្គមត្រូវការជាបន្ទាន់នូវស្ដង់ដារួមសម្រាប់ប្រព័ន្ធ ICT រួមមាននិយមន័យនៃលក្ខខណ្ឌតម្រូវការទិន្នន័យអប្បបរមា, គោលការណ៍ណែនាំប្រតិបត្តិសម្រាប់ដំណើរការទិន្នន័យ ជាពិសេសរវាងតួអង្គគាំពារសង្គមផ្សេងៗគ្នា, និងស្ដង់ដាសម្រាប់ការផ្លាស់ប្ដូរទិន្នន័យដោយប្រើប្រាស់ថ្នាល CamDX។ ស្ថានភាពបច្ចុប្បន្ន, តួអង្គគាំពារសង្គមនីមួយៗបានកំណត់និយមន័យ និងស្ដង់ដាទិន្នន័យរៀងៗខ្លួន ដោយតម្រូវទៅតាមប្រភេទនៃទិន្នន័យដែលពួកគេត្រូវការ។ ការផ្លាស់ប្ដូរទិន្នន័យធ្វើឡើងដោយគ្មានផែនការច្បាស់លាស់ និងដោយផ្អែកតាមតម្រូវការជាក់ស្ដែង ឬដោយផ្ទាល់រវាងតួអង្គនីមួយៗ។ បច្ចុប្បន្ននេះ ការផ្លាស់ប្ដូរទិន្នន័យបានធ្វើឡើង តាមរយៈវិធីសាស្ត្រជាច្រើនដែលប្រើប្រាស់ថ្នាលផ្លាស់ប្ដូរទិន្នន័យរួម CamDx ដែលក្នុងនេះមានករណីមួយចំនួនតូចតែប៉ុណ្ណោះ។

សកម្មភាពអាទិភាពនេះ មានគោលបំណងបង្កើតគោលនយោបាយមួយដែលច្បាស់លាស់លើប្រធានបទនេះ ដើម្បីឱ្យទិន្នន័យត្រូវបានសម្អាត និងតម្រឹមបានល្អប្រសើរសម្រាប់តួអង្គគាំពារសង្គម និងប្រព័ន្ធ ICT របស់ពួកគេទាំងអស់។

## សកម្មភាពអាទិភាពទី៣៖ អភិវឌ្ឍគោលនយោបាយ ស្ដីពីការការពារទិន្នន័យ និង សន្តិសុខសាយប័រ

ការការពារទិន្នន័យមានសារៈសំខាន់បំផុតនៅក្នុងប្រព័ន្ធគាំពារសង្គម ព្រោះវាពាក់ព័ន្ធនឹងការប្រមូល, ដំណើរការ, និងរក្សាទុកទិន្នន័យអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។ សំណុំទិន្នន័យជាធម្មតាមានភាពចម្រុះ ហើយបរិមាណទិន្នន័យក៏មានទំហំធំ ដែលមានកំណត់ត្រាពាក់ព័ន្ធនឹងមនុស្សរាប់លាននាក់។ ជារឿយៗទិន្នន័យត្រូវបានប្រមូល ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ហើយចំណេះដឹងរបស់ប្រតិបត្តិករ និងប្រជាជនអំពីសិទ្ធិ និងការបារម្ភនៃការការពារទិន្នន័យនៅមានកំណត់ ដោយសារតែគ្មានការណែនាំសមស្របអំពីការប្រើប្រាស់ទិន្នន័យ។

ក្នុងយុគសម័យឌីជីថលនេះ, ក្ដីបារម្ភអំពីសន្តិសុខសាយប័រមានការកើនខ្លាំង។ ដោយសមត្ថភាពរបស់តួអង្គគាំពារសង្គមនៅមានកម្រិតសម្រាប់ផ្នែកសន្តិសុខសាយប័រ, ការការពារប្រព័ន្ធ ICT ក៏នៅមានកម្រិតផងដែរក្នុងការប្រឆាំងនឹងការវាយប្រហារសាយប័រ។ ការពង្រឹងផ្នែកនេះ មានភាពចាំបាច់ និងត្រូវធ្វើឱ្យបាន

ឆាប់រហ័ស ដើម្បីជៀសវាងការរំខានធ្ងន់ធ្ងរណាមួយដល់ប្រតិបត្តិការ ដោយសារតែការវាយប្រហារសាយប័រ ឬការលួចប្រើប្រាស់ទិន្នន័យឯកជន ដោយគ្មានការអនុញ្ញាត។ ការអភិវឌ្ឍគោលនយោបាយ ស្តីពីការការពារទិន្នន័យ និងសន្តិសុខសាយប័រសម្រាប់ប្រព័ន្ធគាំពារសង្គម នឹងត្រូវអភិវឌ្ឍឱ្យស្របទៅតាមអភិក្រម និងសកម្មភាពទាំងឡាយនៃក្របខណ្ឌគតិយុត្ត និងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

## សកម្មភាពអាទិភាពទី៤៖ អភិវឌ្ឍគោលនយោបាយ ស្តីពីនិម្មាបនកម្ម, ហេដ្ឋារចនាសម្ព័ន្ធ, បណ្តុំបច្ចេកវិទ្យា, និងការផ្ទុក/ការរក្សាទុកទិន្នន័យនៃប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គម

គោលនយោបាយ ស្តីពីនិម្មាបនកម្ម, ហេដ្ឋារចនាសម្ព័ន្ធ, បណ្តុំបច្ចេកវិទ្យា, និងការផ្ទុក/ការរក្សាទុកទិន្នន័យនៃប្រព័ន្ធ ICT នៃប្រព័ន្ធគាំពារសង្គម ត្រូវតែធ្វើការសម្រិតសម្រាំង និងធ្វើយ៉ាងណាឱ្យក្លាយទៅជាឯកសារគោលនយោបាយមួយ។ ព័ត៌មានបន្ថែម ត្រូវដាក់ចូលនៅក្នុងគោលនយោបាយនេះ ដូចជានិយមន័យនៃស្តង់ដាអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធ, បច្ចេកវិទ្យាដែលបានណែនាំសម្រាប់ប្រើប្រាស់, និងការពន្យល់លម្អិតអំពីស្រទាប់ទំនាក់ទំនង (Communication Layer)។ ទាំងនេះរួមបញ្ចូលផងដែរនូវរបៀបដែលទិន្នន័យ និងប្រព័ន្ធប្រតិបត្តិការត្រូវបានដាក់ឱ្យដំណើរការ ដោយសារបច្ចុប្បន្ននេះមានវិធីសាស្ត្រផ្សេងៗត្រូវបានចាប់យក រាប់ចាប់ពីការរក្សាទុកនៅក្នុងមជ្ឈមណ្ឌលទិន្នន័យផ្ទាល់ខ្លួន រហូតដល់ការរក្សាទុកនៅទីតាំងក្រៅប្រទេស តាមរយៈការទិញសេវាកម្មពីអ្នកផ្គត់ផ្គង់សេវា។ បើគ្មានការយល់ស្របគ្នាលើនិម្មាបនកម្ម ICT ដែលមាននិយមន័យច្បាស់លាស់នោះទេ តួអង្គគាំពារសង្គម នឹងបង្កើតប្រព័ន្ធ ICT ផ្ទាល់ខ្លួនរបស់ពួកគេ ដោយគ្មានទស្សនៈទូលំទូលាយ ដើម្បីចាប់យកប្រភេទនៃវិធីសាស្ត្រ និងបច្ចេកវិទ្យាដែលត្រឹមត្រូវ ដែលអាចក្លាយជាផ្នែកមួយក្នុងប្រព័ន្ធអេកូឡូស៊ីគាំពារសង្គមឌីជីថលរួមឡើយ។

## សកម្មភាពអាទិភាពទី៥៖ អភិវឌ្ឍក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ

សកម្មភាពអាទិភាពនេះ បង្កើតឡើងក្នុងគោលដៅធានាថាគោលនយោបាយផ្សេងៗដែលបានអនុម័តត្រូវបានអនុវត្តបានខ្ជាប់ខ្ជួន។ ដោយសារតួអង្គគាំពារសង្គមជាច្រើនបានដំណើរការប្រព័ន្ធ ICT ផ្សេងៗគ្នា, ការអនុវត្តតាមគោលការណ៍ថ្មីៗ អាចត្រូវការពេល និងធនធាន។ យោងតាមហេតុផលនេះ ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ នឹងត្រូវបានបង្កើតឡើងផងដែរ ដែលនឹងអនុញ្ញាតឱ្យអង្គភាពដែលទទួលខុសត្រូវ ដូចជាក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមរបស់រាជរដ្ឋាភិបាល ធ្វើការតាមដានការអនុវត្តគោលនយោបាយនានាលើប្រព័ន្ធគាំពារសង្គមឌីជីថល។ តម្រូវការធនធានបន្ថែមអាចនឹងមាន ដើម្បីបំពេញចំណុចខ្វះចន្លោះ នៃការអនុវត្តគោលនយោបាយ ហើយធនធាននេះ នឹងត្រូវបានបង្ហាញនៅក្នុងផែនការអភិវឌ្ឍ ដោយនឹងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT ក្រោមគោលដៅយុទ្ធសាស្ត្រទី២ នៃឯកសារផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលនេះ។

## ២.៣.២ ការអភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូលក្នុងក្របខណ្ឌគាំពារសង្គមឌីជីថល




ការវាយតម្លៃស្ថានភាពបានបង្ហាញថា ការពង្រឹងសមត្ថភាពធនធានមនុស្សជាកិច្ចការដែលចាំបាច់បំផុតដោយបរិវត្តកម្មឌីជីថល និងប្រព័ន្ធគាំពារសង្គម ជាប្រធានបទមួយថ្មីនៅឡើយក្នុងប្រទេសកម្ពុជា។ ដូចនេះ, ការរួមបញ្ចូលគ្នា និងការផ្តល់នូវចំណេះដឹងអំពីប្រធានបទទាំងពីរនេះ ជាកត្តាចាំបាច់ដើម្បីជំរុញការធ្វើបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមឱ្យទទួលបានជោគជ័យ។

កង្វះធនធានមនុស្សអាចត្រូវបានបែងចែកជាពីរផ្នែកធំៗគឺ៖

**ផ្នែកទី១ ចំនួនបុគ្គលិកដែលមានស្រាប់៖** តួអង្គគាំពារសង្គមទាមទារឱ្យចំនួនមុខតំណែង និងមន្ត្រីបន្ថែម ដោយការជ្រើសរើសអ្នកជំនាញជាបុគ្គលិកជាប់កិច្ចសន្យាអាចជាជម្រើសមួយ។

**ផ្នែកទី២ គុណវុឌ្ឍិនៃបុគ្គលិក៖** អ្នកដែលកំពុងបំពេញការងារក្នុងមុខតំណែងបច្ចុប្បន្ន មិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់នៅឡើយ ដោយហេតុថាពួកគេ ជាទូទៅមានជំនាញក្នុងវិស័យផ្សេងក្រៅពីឌីជីថល។ បុគ្គលិកមួយចំនួន មានជំនាញបច្ចេកទេស ICT ដែរ ប៉ុន្តែចំណេះដឹងសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍយុទ្ធសាស្ត្រ, ការគ្រប់គ្រងគម្រោង, និងការបង្កើតគោលនយោបាយជាដើមនៅមានកម្រិតនៅឡើយ។ កិច្ចខិតខំក្នុងការធ្វើបរិវត្តកម្មឌីជីថល តម្រូវឱ្យមានការធ្វើពិពិធកម្មជំនាញ ព្រោះក្រុមការងារដែលមានសមត្ថភាព និងជំនាញផ្សេងៗគ្នា ជាកត្តាដ៏សំខាន់ដែលអាចធ្វើឱ្យកិច្ចខិតខំក្នុងការធ្វើបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមទទួលបានជោគជ័យ។




*ដ្យាក្រាម៖ ពិពិធកម្មនៃគុណវុឌ្ឍិ និងចំណេះដឹងដែលតម្រូវឱ្យមានសម្រាប់ការធ្វើបរិវត្តកម្មឌីជីថលគាំពារសង្គម*

គោលដៅយុទ្ធសាស្ត្រទី២ ជាការលើកកម្ពស់សមត្ថភាពធនធានមនុស្ស ដើម្បីធានាថាមានធនធានមនុស្សគ្រប់គ្រាន់ សម្រាប់ជំរុញឱ្យការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធគាំពារសង្គមទទួលបានជោគជ័យ។ សកម្មភាពអាទិភាពខាងក្រោមនេះ នឹងត្រូវអនុវត្តស្របជាមួយឧត្តមានុវត្តន៍អន្តរជាតិ ហើយសកម្មភាពអាទិភាពទាំងនេះ នឹងបង្កើនឱកាសសម្រាប់ការរៀនសូត្រពីគ្នាទៅវិញទៅមកផងដែរ។

## សកម្មភាពអាទិភាពទី១៖ ធ្វើការវិភាគចំណុចខ្វះចន្លោះនៃសមត្ថភាពធនធានមនុស្ស

ការវិភាគចំណុចខ្វះចន្លោះសមត្ថភាពធនធានមនុស្សក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល នឹងត្រូវធ្វើឡើងដើម្បីកំណត់អំពីស្ថានភាពពាក់ព័ន្ធនឹងតម្រូវការធនធានមនុស្ស, ឧបសគ្គក្នុងការទទួលបានធនធានបន្ថែម, បញ្ហាប្រឈមនៃការរក្សា និងការអភិវឌ្ឍធនធានមនុស្ស, និងចំណុចខ្វះចន្លោះនៃកម្រិតគុណវុឌ្ឍិ ជំនាញ និងសមត្ថភាពរបស់បុគ្គលិកបច្ចុប្បន្ន ធៀបនឹងតម្រូវការជាក់ស្តែង។ ការវិភាគនេះ នឹងរួមបញ្ចូលនូវក្របខណ្ឌនៃការអភិវឌ្ឍសមត្ថភាព និងគុណវុឌ្ឍិសម្រាប់តួអង្គគាំពារសង្គមទាំងអស់។

## កម្មភាពអាទិភាពទី២៖ រៀបចំផែនការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

ការរកឃើញចំណុចខ្វះចន្លោះក្នុងសកម្មភាពអាទិភាព២ នេះ នឹងត្រូវបានប្រើប្រាស់សម្រាប់រៀបចំផែនការអភិវឌ្ឍសមត្ថភាពអន្តរស្ថាប័ន ក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិគាំពារសង្គម។ សកម្មភាពអាទិភាពប្រកបដោយសក្តានុពល នៅក្នុងផែនការអភិវឌ្ឍសមត្ថភាពនេះ នឹងរួមបញ្ចូលនូវអនុសាសន៍សម្រាប់ការលើកកម្ពស់សមត្ថភាពធនធានមនុស្សសំខាន់ៗ ដូចជាការរៀបចំផែនការវិនិយោគ, ការរៀបចំការងារជាមួយបុគ្គលិកជាប់កិច្ចសន្យា, ការសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីជ្រើសរើស និងរក្សាបុគ្គលិកឱ្យបានប្រសើរជាងមុន, ការធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍, និងកិច្ចសហការជាមួយវិស័យឯកជន។

ផែនការអភិវឌ្ឍសមត្ថភាពអន្តរស្ថាប័នក៏នឹងបញ្ចូលនូវសកម្មភាពផ្សេងទៀតដែលអាចជួយបង្កើន ចំណេះដឹង និងជំនាញរបស់មន្ត្រី ឬបុគ្គលិកដែលមានស្រាប់បច្ចុប្បន្ន។ ផែនការនេះ រួមមានការ បណ្តុះបណ្តាល ស្តីពីបរិវត្តកម្មឌីជីថល, ប្រព័ន្ធគាំពារសង្គមឌីជីថល, ចំណេះដឹងមូលដ្ឋានអំពី ICT, ការគ្រប់គ្រងគម្រោង, និងឧត្តមានុវត្តន៍នានា (ផ្អែកលើគោលការណ៍នៃការអភិវឌ្ឍឌីជីថល)។ កិច្ចសហប្រតិបត្តិការយ៉ាងសកម្ម និងការរៀនសូត្រពីបទពិសោធជាអន្តរជាតិ ក៏នឹងត្រូវធ្វើឡើងផងដែរ។ ការចូលរួមក្នុងសកម្មភាពអាទិភាពជាអន្តរជាតិ ដូចជាវេទិកាគាំពារសង្គមសកលឆ្នាំ ២០៣០[1], ការរួមបញ្ចូលគ្នានៃឌីជីថល, និងការចូលរួមយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើម socialprotection.org នឹងជួយឱ្យប្រតិបត្តិករគាំពារសង្គមឌីជីថលកម្ពុជា ពង្រីកទស្សនៈ និងទទួលបានមេរៀនល្អៗពីឆាកអន្តរជាតិ។

កត្តាសំខាន់មួយទៀតដែលនាំទៅភាពជោគជ័យនៃការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពអន្តរស្ថាប័ននេះ គឺការបង្កើតសហគមន៍នៃអ្នកអនុវត្តក្នុងប្រព័ន្ធគាំពារសង្គម។ សហគមន៍នេះ នឹងបម្រើជាវេទិកាមួយ ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែប្រសើរឡើង និងជំរុញការសិក្សារួមគ្នា តាមរយៈការចែករំលែកបទពិសោធ និងជំនាញនានា។ ក្នុងវេទិកានេះ, ប្រព័ន្ធចែករំលែកចំណេះដឹងរួមមួយ នឹងត្រូវបានបង្កើតឡើង ជាឧបករណ៍មួយសម្រាប់ផ្តល់នូវចំណេះដឹងដល់ប្រតិបត្តិករគាំពារសង្គមយ៉ាងមានប្រសិទ្ធភាព។ ប្រព័ន្ធនេះនឹងមានភាពសាមញ្ញ ដោយប្រើប្រាស់ប្រព័ន្ធដែលកំពុងមានភាពពេញនិយមនៅកម្ពុជា។

## សកម្មភាពអាទិភាពទី៣៖ បង្កើនសមត្ថភាពប្រជាជនគោលដៅក្នុងការប្រើប្រាស់ឧបករណ៍ និងសេវាកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម

ខណៈដែលការធ្វើបរិវត្តកម្មឌីជីថលសម្រាប់ប្រព័ន្ធគាំពារសង្គម មានសន្ទុះឆាប់រហ័ស, សមត្ថភាពរបស់ប្រជាជនក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលពិតជាមានសារៈសំខាន់។ សេវាគាំពារសង្គមតាមរយៈប្រព័ន្ធឌីជីថល បាន និងកំពុងត្រូវបានដាក់ឱ្យដំណើរការសម្រាប់កម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមមួយចំនួននៅកម្ពុជា ដូចជាសមាជិក NSSF និងប្រព័ន្ធ IDPoor ជាដើម។ ការបើកផ្តល់សាច់ប្រាក់តាមបែបឌីជីថលពីរាជរដ្ឋាភិបាលទៅប្រជាជន (Digital Government-to-Person Payments) ក៏នឹងកាន់តែមានវិសាលភាពធំទូលាយនៅពេលដែលប្រព័ន្ធហិរញ្ញវត្ថុឌីជីថលបន្តរីកចម្រើន។ ទំនាក់ទំនងរវាងប្រជាជន ជាមួយនឹងប្រតិបត្តិករនៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមក៏នឹងមានប្រសិទ្ធភាព និងមានភាពងាយស្រួលជាងមុនផងដែរ ដោយការចូលទៅប្រើប្រាស់អាចប្រព្រឹត្តទៅបានតាមរយៈប្រព័ន្ធអនឡាញ ដោយនឹងបានលុបបំបាត់នូវឧបសគ្គនៃកត្តាភូមិសាស្ត្រ និងផ្តល់ឱកាសឱ្យប្រជាជនងាយស្រួលក្នុងការសួរសំណួរ និងស្នើសុំការសម្របសម្រួល និងដំណោះស្រាយ។

សកម្មភាពសំខាន់ៗដែលមានគោលបំណងលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់ប្រជាជន ក៏ដូចជាមន្ត្រីថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់សេវាគាំពារសង្គមឌីជីថលនឹងត្រូវធ្វើឡើង។ សកម្មភាពទាំងនោះមានសារៈសំខាន់ ជាពិសេសសម្រាប់ប្រជាជនដែលមានកម្រិតចំណេះដឹងទាបផ្នែកឌីជីថល។

1 *កិច្ចគាំពារសង្គមជាសកលឆ្នាំ 2030 (www.usp2030.org) ជាដៃគូសកលដើម្បីឈានទៅការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ១.៣៖ អនុវត្តប្រព័ន្ធ និងវិធានការណ៍គាំពារសង្គមដែលសមស្របតាមថ្នាក់ជាតិសម្រាប់ទាំងអស់គ្នា ហើយនៅឆ្នាំ 2030 សម្រេចបាននូវការគាំពារដល់ជនក្រីក្រ និងជនងាយរងគ្រោះ។ នៅក្នុងនោះ គំនិតផ្តួចផ្តើមកំណត់ស្តង់ដាររួមឌីជីថល Digital Convergence (www.sp-convergence.org) ផ្តោតលើការបង្កើតឱ្យមានឯកភាពជាសកលលើស្តង់ដា និងគោលការណ៍ណែនាំសម្រាប់ប្រព័ន្ធព័ត៌មានគាំពារសង្គម។*

សកម្មភាពទាំងនោះរួមមានយុទ្ធនាការផ្សព្វផ្សាយ, សកម្មភាពលើកកម្ពស់ការយល់ដឹងកម្រិតមូលដ្ឋាន, និងការផ្តល់សិទ្ធិអំណាចដល់អន្តរការី ដូចជាអាជ្ញាធរភូមិ-ឃុំ-សង្កាត់ ដើម្បីជួយបង្កើតសមត្ថភាពពលរដ្ឋក្នុងមូលដ្ឋានរបស់ពួកគេ។

## ២.៣.៣ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធព័ត៌មានវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ចំណុចស្នូលនៃបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម គឺប្រព័ន្ធ ICT ដែលរួមមានឧបករណ៍ដូចជាម៉ាស៊ីនមេ ( Server ), កុំព្យូទ័រ, និងទូរស័ព្ទស្មាតហ្វូន អាចដំណើរការកម្មវិធី Software ដែលអាចផ្លាស់ប្តូរទិន្នន័យតាមរយៈអ៊ីនធឺណិត ឬបណ្តាញកុំព្យូទ័រ។ ប្រព័ន្ធ ICT ទាំងនេះ បង្កើនល្បឿនដំណើរការនៃការងារ, គណនាដោយស្វ័យប្រវត្តិ, ផ្តល់ទិន្នន័យត្រឹមត្រូវ និងទាន់ពេល, សម្រាលបន្ទុកការងាររដ្ឋបាល, និងធ្វើឱ្យមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ផងដែរ។ ដំណើរការប្រព័ន្ធឌីជីថលពិតជាបានផ្តល់នូវគុណសម្បត្តិជាច្រើនសម្រាប់បុគ្គលិកដែលជាប្រតិបត្តិករនៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម និងអត្ថគាហក ឬប្រជាជនគោលដៅនៃសេវាគាំពារសង្គម។ សំខាន់ជាងនេះទៅទៀត ប្រព័ន្ធឌីជីថលអាចធ្វើឱ្យប្រព័ន្ធទាំងមូលមានតម្លាភាព និងគណនេយ្យភាពប្រសើរជាងមុន។

ប្រតិបត្តិករនៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមមួយចំនួន ដូចជា MoP (IDPoor), NSAF, និង NSSF បានធ្វើឌីជីថលូបនីយកម្មក្នុងកម្រិតខ្ពស់រួចទៅហើយ ខណៈដែលប្រតិបត្តិករមួយចំនួនទៀតស្ថិតក្នុងដំណាក់កាលដំបូងនៃការផ្លាស់ប្តូរពីដំណើរការដោយដៃ និងកំណត់ត្រាផ្អែកលើក្រដាស។ ប្រតិបត្តិករគាំពារសង្គមភាគច្រើនផ្សេងទៀត ស្ថិតនៅចន្លោះរវាងកម្រិតដំបូង និងកម្រិតខ្ពស់នៃការធ្វើឌីជីថលូបនីយកម្ម។ ប្រតិបត្តិករគាំពារសង្គមនីមួយៗបានចាប់យកនូវឧបករណ៍ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលខុសគ្នាផងដែរ។ ប្រតិបត្តិករគាំពារសង្គមផ្សេងៗគ្នាបានប្រើប្រាស់អភិក្រមខុសៗគ្នាក្នុងលក្ខខណ្ឌនៃប្រភេទបច្ចេកវិទ្យា និងរបៀបដែលប្រព័ន្ធនោះត្រូវបានដំណើរការ និងគ្រប់គ្រង។ ការរក្សាទុកទិន្នន័យបម្រុង ជាផ្នែកមួយដែលត្រូវបានគេសង្កេតឃើញថាតម្រូវឱ្យមានការពង្រឹងបន្ថែម។ ក្នុងទិដ្ឋភាពរួម, ដោយនិម្មាបនកម្មប្រព័ន្ធគាំពារសង្គមទាំងមូលស្ថិតក្នុងដំណាក់កាលក្មេងខ្ចីនៅឡើយ, ប្រតិបត្តិករគាំពារសង្គមនីមួយៗ មិនទាន់បានចាប់ផ្តើមធ្វើការសកម្មជាមួយគ្នា ដើម្បីឆ្ពោះទៅការធ្វើសុខដុមនីយកម្មប្រព័ន្ធទាំងមូលនៅឡើយ។ ការផ្លាស់ប្តូរទិន្នន័យរវាងប្រតិបត្តិករគាំពារសង្គមនីមួយៗមិនទាន់បានធ្វើឡើងលក្ខណៈជាប្រព័ន្ធដោយប្រើប្រាស់ថ្នាល CamDx ហើយការប្រើប្រាស់សេវាកម្មរួម ដូចជាច្រកទូទាត់សងប្រាក់ និងការចុះបញ្ជីរួមបែបសមាហរណ មិនទាន់ត្រូវបានប្រើប្រាស់ពេញលេញផងដែរ។

ដើម្បីពង្រឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បានបង្កើតនិម្មាបនកម្មប្រព័ន្ធ ICT ដោយផ្អែកលើឧត្តមានុវត្តន៍អន្តរជាតិដែលផ្តល់នូវក្របខណ្ឌទស្សនាទានអំពីរបៀបដែលប្រព័ន្ធ ICT ផ្សេងៗគ្នា អាចរួមធ្វើការជាមួយគ្នា និងតម្រង់ផ្លូវនៃការអភិវឌ្ឍប្រព័ន្ធនីមួយៗ ដើម្បីឆ្ពោះទៅប្រព័ន្ធមួយប្រកបដោយភាពសុខដុម។




ដ្យាក្រាម៖ និម្មាបនកម្មប្រព័ន្ធ ICT សម្រាប់ប្រព័ន្ធគាំពារសង្គមកម្ពុជា

គោលដៅយុទ្ធសាស្ត្រទី៣ នឹងផ្តោតលើការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីឆ្ពោះទៅនិម្មាបនកម្មប្រព័ន្ធ ICT ប្រកបដោយភាពសុខដុម។

## សកម្មភាពអាទិភាពទី១៖ ធ្វើការវិភាគភាពខ្វះចន្លោះ និងកំណត់អាទិភាពនៃប្រព័ន្ធព័ត៌មានវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ព័ត៌មានលម្អិតអំពីស្ថានភាពបច្ចុប្បន្ន ពិតជាមានភាពចាំបាច់ណាស់ក្នុងការយកមកប្រើប្រាស់ ដើម្បីរៀបចំគម្រោងកែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ កិច្ចការទី១ដែលត្រូវធ្វើគឺការវិភាគមួយដែលអាចមើលឃើញស៊ីជម្រៅទៅក្នុងស្ថានភាពឌីជីថលរបស់ប្រតិបត្តិករគាំពារសង្គមនីមួយៗលើចំនុច ដូចខាងក្រោម៖

- ប្រភេទនៃប្រព័ន្ធ ICT ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ (មុខងារ និងលក្ខណៈពិសេស, ភាសាដែលបានប្រើប្រាស់ដើម្បីបង្កើតកម្មវិធី និងមូលដ្ឋានទិន្នន័យ, និងចំណុចខ្វះខាតផ្សេងៗ);
- ការដំឡើងហេដ្ឋារចនាសម្ព័ន្ធ;
- ទិដ្ឋភាពបរិស្ថាននៃប្រតិបត្តិការ ICT ទាំងមូល;
- សមត្ថភាព និងភាពខ្វះចន្លោះនៃក្រុមការងារ និងនាយកដ្ឋាន ICT;
- កម្រិតសន្តិសុខសាយប័រ;
- យន្តការនៃការចូលប្រើប្រាស់ និងការផ្លាស់ប្តូរទិន្នន័យ;
- ផែនការអភិវឌ្ឍន៍នាពេលអនាគត និងគម្លាតថវិកា; និង
- មេរៀនទទួលបានពីបទពិសោធនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

ការវិភាគនេះ នឹងរួមបញ្ចូលការពិនិត្យមើលប្រព័ន្ធឌីជីថលដែលអាចប្រើប្រាស់បាន និងមានស្រាប់ (រួមទាំងសមត្ថភាពមនុស្ស)។ ក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ អង្គការមិនមែនរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍នៅក្នុងប្រទេសជាច្រើនបានចូលរួមក្នុងការរចនា និងធ្វើប្រតិបត្តិការកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដើម្បីជួយប្រជាជនគោលដៅ។ ឧបករណ៍ឌីជីថល និងសមត្ថភាព ឬជំនាញដែលមានស្រាប់នៅក្នុងតួអង្គទាំងនោះ អាចរួមចំណែក និងជំរុញកិច្ចខិតខំធ្វើបរិវត្តកម្មឌីជីថលគាំពារសង្គមផងដែរ។

## សកម្មភាពអាទិភាពទី២៖ អភិវឌ្ឍផែនការវិនិយោគសម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT

គម្រោងកែលម្អប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលបាន និងកំពុងអនុវត្តនាបច្ចុប្បន្ននេះ ត្រូវបានធ្វើឡើង ដោយពុំមានផែនការច្បាស់លាស់ ដែលជាធម្មតាអាស្រ័យលើប្រតិបត្តិករគាំពារសង្គមណាមួយមានតម្រូវការ, ធនធានក្នុងការអភិវឌ្ឍ, និងលទ្ធភាពអនុវត្ត។ ការវិនិយោគភាគច្រើនលើការកែលម្អប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍន៍។ ការណ៍នេះ ទាមទារឱ្យមានកិច្ចសហការលក្ខណៈជាប្រព័ន្ធបន្ថែមទៀត ដើម្បីធានាថាធនធានដែលមានស្រាប់ ត្រូវបានវិនិយោគទៅលើផ្នែកដែលបន្ទាន់បំផុត។

តាមរយៈលទ្ធផលនៃការវិភាគ, ផែនការអភិវឌ្ឍន៍ និងការវិនិយោគសម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតនៃប្រព័ន្ធ ICT និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល នឹងត្រូវបានអភិវឌ្ឍឡើង។ ផែនការអភិវឌ្ឍន៍ ICT នឹងក្លាយជាមូលដ្ឋានគាំទ្រដ៏សំខាន់សម្រាប់ការវិនិយោគបន្ថែមទៀត និងការសម្របសម្រួលជំនួយពីដៃគូអភិវឌ្ឍន៍នានា។ ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមរបស់រាជរដ្ឋាភិបាល និងរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមនឹងគាំទ្រ និងធ្វើសកម្មភាពយ៉ាងសកម្ម ដើម្បីស្វែងរកមូលនិធិ និងធនធានគាំទ្រសកម្មភាពទាំងអស់នេះ។ នៅក្នុងផែនការនេះ និរន្តរភាពនៃការវិនិយោគជាធាតុសំខាន់ដែលត្រូវតែសង្កត់ធ្ងន់។

## សកម្មភាពអាទិភាពទី៣៖ អភិវឌ្ឍផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT

បន្ទាប់ពីផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT ត្រូវបានអនុម័ត, ការអនុវត្តផែនការនេះនឹងត្រូវបានចាប់ផ្ដើម ដែលនឹងទាមទារជំនាញគ្រប់គ្រងគម្រោង ICT ដោយរំពឹងថា សកម្មភាពអាទិភាពទាំងនេះនឹងត្រូវដឹកនាំដោយក្រុមការងារ ឬនាយកដ្ឋាន ICT នៃតួអង្គគាំពារសង្គមនីមួយៗ ប៉ុន្តែនឹងមានការជួយគាំទ្របន្ថែមពីក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមរបស់រាជរដ្ឋាភិបាល និងក្រុមការងារស្នូលគាំពារសង្គមឌីជីថលនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ កិច្ចខិតខំអនុវត្តគម្រោងទាំងនេះ នឹងក្លាយជាឱកាសដ៏សំខាន់សម្រាប់ការធ្វើឌីជីថលូបនីយកម្មក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល។ ការចូលរួមយ៉ាងសកម្មរបស់ភាគីពាក់ព័ន្ធផ្សេងទៀត នឹងអនុញ្ញាតឱ្យពួកគេទទួលបានការគាំទ្របន្ថែម និងអាចរៀនសូត្រពីឧត្តមានុវត្តន៍តាមរយៈការអនុវត្តការងាររួមគ្នា។

សកម្មភាពអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលមួយចំនួនបាន និងកំពុងដំណើរការរួចទៅហើយបច្ចុប្បន្ននេះ។ សកម្មភាពទាំងនេះ នឹងត្រូវបានរួមបញ្ចូលទៅក្នុងផែនការរួម ហើយបន្តធ្វើការអភិវឌ្ឍឱ្យកាន់តែប្រសើរឡើង តាមរយៈការទទួលបានធនធានបន្ថែម និងកិច្ចខិតខំអនុវត្តរួមគ្នា។ ទន្ទឹមនេះ, ការងារអាទិភាព គឺត្រូវធានាថាគម្រោងទាំងនោះ នឹងបញ្ចប់ដោយជោគជ័យ ហើយមេរៀនដែលបានទទួលពីគម្រោងទាំងនោះត្រូវបានចងក្រងជាឯកសារ។ គម្រោងអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT ដែលកំពុងដំណើរការនៅក្នុងប្រព័ន្ធគាំពារសង្គម រួមមាន៖

- ការធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជីគាំពារសង្គម ដោយរួមបញ្ចូលគ្នារវាងប្រព័ន្ធចុះបញ្ជីសង្គម និងប្រព័ន្ធចុះបញ្ជីអត្ថគាហក ឬអ្នកទទួលផល;
- ប្រព័ន្ធ IDPoor នៃ MoP (ការកែតម្រូវឆ្ពោះទៅយន្តការតាមការស្នើសុំ និងកម្មវិធីទូរសព្ទសម្រាប់អ្នកកាន់បណ្ណសមធម៌);
- ប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ នៃទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ (ការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តផ្នែកខាងក្រោយ (back-end) នៃ PMRS);
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងធនធានមនុស្សនៃ NSSF (ការរៀបចំរចនាសម្ព័ន្ធឡើងវិញ/ការធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធដែលមានស្រាប់);
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ នៃ NSAF (ការកែតម្រូវឆ្ពោះទៅកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ);

- កម្មវិធីអាហារូបករណ៍របស់ MoEYS និង SFIS (គម្រោងធ្វើការកែលម្អឆ្ពោះទៅការធ្វើស្វ័យប្រវត្តិកម្មបន្ថែមទៀត); និង
- ប្រព័ន្ធអត្តសញ្ញាណកម្មពិការភាពរបស់ MoSVY។

គុណសម្បត្តិនៃផែនការអភិវឌ្ឍន៍ នឹងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT មានដូចខាងក្រោម៖

- គម្រោងទាំងអស់ នឹងត្រូវបានជំរុញ និងដឹកនាំដោយតួអង្គពាក់ព័ន្ធជាម្ចាស់នៃប្រព័ន្ធ ICT (ប្រតិបត្តិករគាំពារសង្គមនីមួយៗ) ប៉ុន្តែអាចពឹងផ្អែកលើការគាំទ្រពីតួអង្គផ្សេងទៀត ដូចជាក្នុងក្របខណ្ឌនៃយន្តការស្ថាប័នរួមពាក់ព័ន្ធនឹងការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមជាដើម។
- ធ្វើឱ្យការចែករំលែកទិន្នន័យផ្ទៃក្នុង និងរវាងតួអង្គគាំពារសង្គមទាំងអស់កាន់តែប្រសើរឡើង ដោយប្រើប្រាស់ CamDx ជាថ្នាលផ្លាស់ប្តូរទិន្នន័យរួម ក៏ដូចជានឹងរួមចំណែកក្នុងការពង្រឹងគោលការណ៍បញ្ចូលទិន្នន័យតែមួយដង (Only-Once Principle);
- ជំរុញការប្រើប្រាស់ឧបករណ៍ឌីជីថលជាមធ្យោបាយក្នុងការផ្តល់សេវារហ័ស, ងាយស្រួលសម្រាប់អត្ថគាហក ឬអ្នកទទួលផល;
- ជំរុញដំណើរការការងារដោយស្វ័យប្រវត្តិ និងជួយកាត់បន្ថយបន្ទុកការងារសម្រាប់ប្រតិបត្តិករគាំពារសង្គម;
- បង្កើតទិសដៅអភិវឌ្ឍន៍រួម ឆ្ពោះទៅប្រព័ន្ធគាំពារសង្គមឌីជីថល ដែលមានភាពសុខដុម និងអាចធ្វើអន្តរប្រតិបត្តិការរវាងគ្នានឹងគ្នាបាន;
- ធ្វើឱ្យប្រសើរឡើងនូវការកំណត់អត្តសញ្ញាណប្រជាជនគោលដៅ, និងអត្ថគាហក ឬអ្នកទទួលផល; និង
- ពង្រឹងមុខងាររក្សាទុកទិន្នន័យបម្រុង នៃហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗដែលប្រើប្រាស់ក្នុងប្រព័ន្ធគាំពារឌីជីថលទាំងមូល។

## សកម្មភាពអាទិភាពទី៤៖ ការកែលម្អការចុះបញ្ជីក្នុងកម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមនានា

ការចុះបញ្ជី គឺជាដំណើរការនៃការចុះឈ្មោះប្រជាជនគោលដៅ, អត្ថគាហក, ឬអ្នកទទួលផលទៅក្នុងកម្មវិធីជាតិជំនួយសង្គម ឬរបបសន្តិសុខសង្គមជាក់លាក់ណាមួយ។ ដំណើរការនេះ រួមបញ្ចូលទាំងដំណើរការកំណត់អត្តសញ្ញាណ ដែលអ្នកផ្តល់សេវា នឹងផ្ទៀងផ្ទាត់អត្តសញ្ញាណ ថាតើបុគ្គលដែលទាមទារអត្ថប្រយោជន៍ ជាបុគ្គលដែលមានសិទ្ធិនឹងទទួលបានតាវកាលិក ឬកញ្ចប់អត្ថប្រយោជន៍ដែរឬទេ។ ការប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម បានផ្តល់ភាពងាយស្រួល តាមរយៈការពង្រឹងគុណភាពសេវាកាន់តែរហ័ស និងប្រសើរឡើងដល់អត្ថគាហក ឬអ្នកទទួលផល និងប្រជាជនគោលដៅ។ ការតភ្ជាប់បែបឌីជីថល រវាងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមបច្ចុប្បន្នទាំងអស់តាមរយៈមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម ដែលអាចបង្កើតនូវលេខសម្គាល់គាំពារសង្គម (SPID) នឹងធ្វើឱ្យរំហូរនៃប្រតិបត្តិការ អាចប្រព្រឹត្តទៅកាន់តែលឿន និងត្រឹមត្រូវជាងមុន។ ដូច្នេះ ការតភ្ជាប់ និងប្រើប្រាស់លេខសម្គាល់គាំពារសង្គមក្នុងប្រព័ន្ធចុះបញ្ជីរបស់ប្រតិបត្តិករផ្សេងៗទៀតនឹងត្រូវអនុវត្ត។

SPID ដែលទើបត្រូវបានបង្កើតថ្មីនេះ នឹងជួយសម្រួលដល់អន្តរប្រតិបត្តិការរវាងប្រព័ន្ធ ICT ដែលមានស្រាប់ទាំងអស់ និងពង្រឹងបន្ថែមទៅលើការផ្ទៀងអត្តសញ្ញាណដែលកំពុងពឹងផ្អែកតែទៅលើអត្តសញ្ញាណបណ្ណសញ្ញាតិខ្មែរ។ SPID នឹងក្លាយទៅជាចំណុចរួម សម្រាប់ទំនាក់ទំនងតែមួយគត់រវាងប្រតិបត្តិករទាំងអស់ក្នុងប្រព័ន្ធគាំពារសង្គម ដែលអនុញ្ញាតឱ្យពួកគេកំណត់អត្តសញ្ញាណប្រជាជនគោលដៅ និងអត្ថគាហក ឬអ្នកទទួលផល ក៏ដូចជាធានាបាននូវបរិយាបន្ន និងការគ្របដណ្តប់ជាអតិបរមា។ អភិក្រមនេះ នឹងជួយកាត់បន្ថយភាពបែកខ្ញែកនៃទិន្នន័យក្នុងអំឡុងពេលចុះបញ្ជីផងដែរ។

ក្នុងគោលដៅរយៈពេលវែង, ដំណោះស្រាយឌីជីថលនេះ នឹងអនុញ្ញាតឱ្យសាធារណជនអាចទទួលបានការចុះឈ្មោះ ដើម្បីទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមដែលអាចទទួលបាន។ **ថ្នាលគាំពារសង្គមឌីជីថល** (Digital Social Protection Platform) ជាមួយនឹងគណនីចូលប្រើប្រាស់តាមប្រព័ន្ធអនឡាញដោយឥតគិតថ្លៃ និងមានសុវត្ថិភាព នឹងផ្តល់ព័ត៌មានសមស្របតាមតម្រូវការរបស់ប្រជាជននូវអត្ថប្រយោជន៍គាំពារសង្គមនានាដែលកំពុងផ្តល់ដោយរាជរដ្ឋាភិបាល។ ប្រជាជនអាចប្រើប្រាស់គណនី ដើម្បីស្នើសុំសេវាគាំពារសង្គម ដូចជាការផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួន និងត្រួតពិនិត្យដំណើរការនៃពាក្យស្នើសុំ ឬដាក់ពាក្យស្នើសុំកញ្ចប់អត្ថប្រយោជន៍គាំពារសង្គម។

កំណត់ត្រាអត្តសញ្ញាណ ដែលបានចុះបញ្ជីតាមរយៈ**ផតថលចុះបញ្ជីរួម** (Single Registration Portal) នៃថ្នាលគាំពារសង្គមឌីជីថល នឹងត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម ហើយត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅក្នុងមូលដ្ឋានទិន្នន័យរបស់ប្រតិបត្តិករគាំពារសង្គមសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការនានា។

**មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម** នឹងត្រូវបានអភិវឌ្ឍឡើងជាដំណាក់កាលៗ ដោយប្រើប្រាស់កំណត់ត្រាអត្តសញ្ញាណប្រជាជនគោលដៅ និងអត្ថគាហក ឬអ្នកទទួលផលពីប្រព័ន្ធទិន្នន័យដែលមានស្រាប់ និងកំណត់ត្រានៃអ្នកដែលមានសិទ្ធិទទួលបានការគាំពារ ដែលមិនទាន់បានចុះបញ្ជីនៅក្នុងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមណាមួយ។

## ២.៣.៤ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការសម្របសម្រួលភាគីពាក់ព័ន្ធនៃកិច្ចខិតខំបរិវត្តកម្មឌីជីថល

កិច្ចសហការយ៉ាងសកម្មរវាងភាគីពាក់ព័ន្ធទាំងអស់ មានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គម ប្រកបដោយភាពជោគជ័យ ដោយសារទំហំនៃការងារ និងចំនួនច្រើននៃតួអង្គដែលទទួលខុសត្រូវ។ គោលដៅយុទ្ធសាស្ត្រទី៤ មានបំណងពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងអស់ក្នុងប្រព័ន្ធគាំពារសង្គម។

ភាគីពាក់ព័ន្ធសំខាន់ៗ រួមមានស្ថាប័ននានារបស់រាជរដ្ឋាភិបាល, អង្គការមិនមែនរដ្ឋាភិបាល, និងវិស័យឯកជនទាំងអស់ ដែលរួមចំណែកក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គមសម្រាប់ប្រជាជនកម្ពុជា តាមរយៈអន្តរាគមន៍ ឬគោលនយោបាយឌីជីថល។

ភាគីពាក់ព័ន្ធនៃប្រព័ន្ធគាំពារសង្គមមាន២ប្រភេទ ដូចខាងក្រោម៖

- *ចូលរួមយ៉ាងសកម្មក្នុងការធ្វើប្រតិបត្តិការ ឬផ្តល់សេវា និងអត្ថប្រយោជន៍; និង*
- *មិនបានចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើប្រតិបត្តិការប៉ុន្តែមានតួនាទីសំខាន់ផ្នែកយុទ្ធសាស្ត្រ ក្នុងការធ្វើឌីជីថលូបនីយកម្មក្នុងប្រព័ន្ធគាំពារសង្គម។*

## សកម្មភាពអាទិភាពទី១៖ អភិវឌ្ឍយន្តការប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងតួអង្គគាំពារសង្គម

យន្តការស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ជាអ្នកត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រនេះ។ នៅក្នុងយន្តការនេះ, ក្រុមការងារទទួលបន្ទុកក្នុងទិដ្ឋភាពផ្សេងៗអាចត្រូវបានបង្កើតឡើង។ ក្រុមការងារ ឬនាយកដ្ឋាន ICT នៃប្រតិបត្តិករទាំងអស់ ដែលជាអ្នករៀបចំផែនការ និងការសម្រេចពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះក្នុងកម្រិតស្ថាប័នរបស់ពួកគេ។ ក្រុមការងារនឹងអនុវត្តមុខងារត្រួតពិនិត្យគម្រោង និងជំរុញកិច្ចខិតខំអនុវត្តយុទ្ធសាស្ត្រនេះ។

ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានអញ្ជើញឱ្យចូលរួមមតិយោបល់ និងធាតុចូលក៏ដូចជាមធ្យោបាយទៅតាមការចាំបាច់។

## សកម្មភាពអាទិភាពទី២៖ អភិវឌ្ឍថ្នាលផ្លាស់ប្តូរព័ត៌មានក្រៅផ្លូវការសម្រាប់អ្នកអនុវត្តប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គមទាំងអស់

ថ្នាលផ្លាស់ប្តូរព័ត៌មានក្រៅផ្លូវការមួយដែលត្រូវបានសម្របសម្រួលដោយក្រុមការងារស្នូលគាំពារសង្គមឌីជីថលប្រចាំ NSPC នឹងត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឱ្យអ្នកអនុវត្ត ICT ក្នុងប្រព័ន្ធគាំពារសង្គមមានការផ្លាស់ប្តូរបទពិសោធ និងរៀនសូត្រជាមួយគ្នា។ ទាំងនេះ គឺជាសហគមន៍អ្នកអនុវត្ត ICT ដែលបានលើកឡើងនៅក្នុងសកម្មភាពអាទិភាព១ នៃគោលដៅយុទ្ធសាស្ត្រទី២។ ក្រៅពីនេះ ឆានែលសម្រាប់ផ្ទុកឯកសារមួយ នឹងត្រូវបង្កើតឡើង និងមានតួនាទីសម្រាប់រក្សា/គ្រប់គ្រងឯកសារសម្រាប់រៀនសូត្ររបស់ក្រុមការងារ។ សហគមន៍អ្នកអនុវត្តនេះ នឹងជួយបង្កើតការគិត និងការឯកភាពគ្នាលើបញ្ហាផ្សេងៗ ហើយការគាំទ្ររវាងគ្នា និងគ្នា ក៏នឹងបង្កើតឡើងតាមរយៈថ្នាលនេះផងដែរ។

# ជំពូកទី៣

# ការអនុវត្ត យុទ្ធសាស្ត្រ



# ៣.១

# តួអង្គ និងតួនាទីសំខាន់ៗ

យន្តការសម្របសម្រួលរបស់រាជរដ្ឋាភិបាលក្នុងការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម នឹងក្លាយជាថ្នាលសម្រាប់ការធ្វើការសម្រេចចិត្តមួយកម្រិត និងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាប្រចាំ។ ក្រុមការងារ ICT នានា រួមមានក្រុមការងារ ឬនាយកដ្ឋាន ICT នៃតួអង្គគាំពារសង្គមសំខាន់ៗទាំងអស់ នឹងក្លាយជាវេទិកាសម្រាប់ការពិភាក្សាយ៉ាងសកម្មក្នុងកម្រិតបច្ចេកទេស។ ដោយសារសកម្មភាពអាទិភាពជាច្រើនដែលអនុវត្តក្រោមយុទ្ធសាស្ត្រនេះ ពាក់ព័ន្ធផ្ទាល់ទៅនឹងក្រុមការងារ ឬនាយកដ្ឋាន ICT នៃតួអង្គគាំពារសង្គមទាំងអស់ការរៀបចំនេះនឹងអនុញ្ញាតឱ្យមានកិច្ចសហការ និងការអនុវត្តយ៉ាងសកម្ម។

ការដឹកនាំប្រតិបត្តិការប្រចាំថ្ងៃពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រ មានក្រុមគន្លឹះចំនួន ២ ដូចខាងក្រោម៖

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាពិសេសក្រុមការងារស្នូលគាំពារសង្គមឌីជីថល នឹងសម្របសម្រួលសកម្មភាព និងការងារអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដែលមានលក្ខណៈជាប្រព័ន្ធ ដូចជាការព្រាងគោលនយោបាយគាំពារសង្គមឌីជីថល និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ប្រព័ន្ធទាំងមូល និងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ; និង
- តួអង្គគាំពារសង្គមដែលមានក្រុមការងារ ឬនាយកដ្ឋាន ICT (ឧទាហរណ៍ NSSF, MoSAVY, NSAF, NPCA, និង MoEYS ឬផ្សេងទៀត) នឹងជំរុញសកម្មភាព និងផែនការប្រតិបត្តិ ក្រោមការត្រួតពិនិត្យរបស់ខ្លួន។ សកម្មភាពទាំងនោះ រួមមានការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ ICT ដើម្បីអនុលោមតាមស្តង់ដាអប្បបរមា និងការកែលម្អមុខងារ និងលក្ខណៈនៃប្រព័ន្ធ ICT ដូច្នេះពួកគេអាចបង្កើនដំណើរការដោយស្វ័យប្រវត្តិ និងការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកបន្ថែមទៀត។

កិច្ចខិតខំអនុវត្តផែនការយុទ្ធសាស្ត្រ អាចទទួលបានអត្ថប្រយោជន៍ពីការគាំទ្រនៃដៃគូអភិវឌ្ឍន៍។ ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការគាំទ្រលើធនធានបន្ថែមពីដៃគូអភិវឌ្ឍន៍ ការសម្របសម្រួល និងការប្រើប្រាស់ធនធាននឹងបង្វែរទៅផ្នែកដែលមានអាទិភាពខ្ពស់។ ការពិភាក្សាត្រូវមានទម្រង់ ដូចខាងក្រោម៖

- កិច្ចពិភាក្សាកម្រិតខ្ពស់ជាមួយដៃគូអភិវឌ្ឍន៍លើយុទ្ធសាស្ត្រនេះត្រូវបានគេរំពឹងថានឹងប្រព្រឹត្តទៅតាមរយៈយន្តការសម្របសម្រួលផ្លូវការក្នុងក្របខណ្ឌ NSPC និងដៃគូអភិវឌ្ឍន៍; និង
- កិច្ចពិភាក្សាកម្រិតប្រតិបត្តិ និងបច្ចេកទេសពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងធ្វើឡើងដោយផ្ទាល់ជាមួយមន្ត្រី ឬបុគ្គលិកប្រតិបត្តិករពាក់ព័ន្ធ ខណៈដែលការពិភាក្សាកម្រិតបច្ចេកទេស អាចធ្វើឡើងទាំងនៅក្នុងយន្តការស្ថាប័នដែលទទួលបន្ទុក និង/ឬក្រុមការងារនានាផងដែរ។

# ៣.២
# ការតាមដាន និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃនឹងធ្វើឡើងដើម្បីធានាថា វឌ្ឍនភាពនៃការអភិវឌ្ឍកំពុងតែដំណើរការស្របតាមផែនការប្រតិបត្តិ និងលក្ខខណ្ឌតម្រូវចុងក្រោយបង្អស់។




## ផែនការប្រតិបត្តិ និងក្របខណ្ឌតាមដាន និងវាយតម្លៃ

យន្តការស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យរបស់រាជរដ្ឋាភិបាលដោយមានជំនួយពីក្រុមការងារ គួរអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីកំណត់អាទិភាព និងផ្តល់នូវសកម្មភាពអាទិភាពផ្សេងៗដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ។ ផែនការប្រតិបត្តិត្រូវកំណត់អំពីសកម្មភាព, បង្គោលចរ, ក្របខណ្ឌពេល, តួអង្គទទួលខុសត្រូវ, លទ្ធផល, និងសូចនាករប្រតិបត្តិការសំខាន់ៗដែលគួរសម្រេចបាន។ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពនឹងត្រូវបានវាយតម្លៃជាប្រចាំ។



## ការវាយតម្លៃយុទ្ធសាស្ត្រ

ក្របខណ្ឌពេលនៃយុទ្ធសាស្ត្រនេះស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានពិនិត្យលើមូលដ្ឋានប្រចាំឆ្នាំស្របតាមផែនការប្រតិបត្តិ។ នៅពេលដែលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមបញ្ចប់តាមពេលកំណត់, ការធ្វើបរិវត្តកម្មឌីជីថលក្នុងផែនការយុទ្ធសាស្ត្រ នឹងត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងទៅនឹងទិសដៅយុទ្ធសាស្ត្រដែលបានដាក់ចេញថ្មីនៅក្នុងបច្ចុប្បន្នកម្មនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

# ឧបសម្ព័ន្ធ១៖
## ម៉ាទ្រីសនៃគោលដៅយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាព

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | បង្គោលចរ | ឆ្នាំសម្រាប់ការអនុវត្ត |
|---|---|---|---|
| ការធ្វើឱ្យកាន់តែប្រសើរនូវគោលនយោបាយ និងក្របខណ្ឌច្បាប់ ក្នុងក្របខណ្ឌគាំពារសង្គមឌីជីថល | **សកម្មភាពអាទិភាពទី១** អភិវឌ្ឍគោលនយោបាយ ស្តីពីការចុះបញ្ជី និងការកំណត់អត្តសញ្ញាណតែមួយគត់សម្រាប់ប្រព័ន្ធគាំពារសង្គម | គោលនយោបាយសម្រាប់ប្រព័ន្ធគាំពារសង្គមទាំងមូលដែលផ្តោតលើការពង្រឹង និងសុខដុមនីយកម្មនៃអភិក្រមទាំងអស់ក្នុងការកំណត់អត្តសញ្ញាណនឹងត្រូវបង្កើតឡើង។ | ២០២៤ - ២០២៦ |
| | **សកម្មភាពអាទិភាពទី២** អភិវឌ្ឍគោលនយោបាយ ស្តីពីស្តង់ដា, ដំណើរការ, និងការផ្លាស់ប្តូរទិន្នន័យរវាងតួអង្គគាំពារសង្គម | គោលនយោបាយស្តីពីស្តង់ដា, ដំណើរការ, និងការផ្លាស់ប្តូរទិន្នន័យរវាងតួអង្គគាំពារសង្គម នឹងត្រូវអភិវឌ្ឍឡើង។ | ២០២៤ - ២០២៦ |
| | **សកម្មភាពអាទិភាពទី៣** អភិវឌ្ឍគោលនយោបាយ ស្តីពីការការពារទិន្នន័យ និងសន្តិសុខសាយប័រ | តួអង្គគាំពារសង្គម មានចំណេះដឹងរឹងមាំលើផ្នែកសន្តិសុខសាយប័រ។ គោលនយោបាយពាក់ព័ន្ធ នឹងត្រូវអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់សម្រាប់តួអង្គពាក់ព័ន្ធក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល។ | ២០២៤ - ២០២៦ |
| | **សកម្មភាពអាទិភាពទី៤** អភិវឌ្ឍគោលនយោបាយ ស្តីពីនិម្មាបនកម្ម, ហេដ្ឋារចនាសម្ព័ន្ធ, បណ្តុំបច្ចេកវិទ្យា, និងការផ្ទុក/ការរក្សាទុកទិន្នន័យនៃប្រព័ន្ធ ICT ក្នុងប្រព័ន្ធគាំពារសង្គម | គោលការណ៍នយោបាយ ស្តីពីនិម្មាបនកម្ម ICT នៃប្រព័ន្ធគាំពារសង្គម នឹងត្រូវអភិវឌ្ឍឡើង។ | ២០២៥ - ២០២៧ |
| | **សកម្មភាពអាទិភាពទី៥** អភិវឌ្ឍក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោល-នយោបាយ | ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយនឹងត្រូវអភិវឌ្ឍឡើង។ ការតាមដាននឹងត្រូវធ្វើឡើងជាប្រចាំ។ | ២០២៥ - ២០២៩ |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | បន្ទោលចរ | ឆ្នាំសម្រាប់ការអនុវត្ត |
|---|---|---|---|
| ការអភិវឌ្ឍសមត្ថភាពសម្រាប់តួអង្គស្នូលក្នុងក្របខណ្ឌគាំពារសង្គមឌីជីថល | **សកម្មភាពអាទិភាពទី១** ធ្វើការវិភាគចំណុចខ្វះចន្លោះនៃសមត្ថភាពធនធានមនុស្ស | ការវិភាគចំណុចខ្វះចន្លោះសមត្ថភាពធនធានមនុស្សជាប្រព័ន្ធ នឹងត្រូវអនុវត្ត បូករួមនឹងការបង្កើតនូវក្របខណ្ឌនៃការអភិវឌ្ឍសមត្ថភាព និងគុណវុឌ្ឍិសម្រាប់ក្រុមការងារ និងនាយកដ្ឋាន ICT នៃតួអង្គការពារសង្គមនានារបស់រាជរដ្ឋាភិបាល។ | ២០២៤ - ២០២៥ |
| | **សកម្មភាពអាទិភាពទី២** រៀបចំផែនការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស | ការបណ្តុះបណ្តាល ស្តីពីបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមឌីជីថល, ចំណេះដឹងមូលដ្ឋានអំពី ICT, ការគ្រប់គ្រងគម្រោង, និងឧត្តមានុវត្តន៍នានា នឹងត្រូវបានធ្វើឡើង។ | ២០២៤ - ២០២៥ |
| | **សកម្មភាពអាទិភាពទី៣** បង្កើនសមត្ថភាពសង្គមក្នុងការប្រើប្រាស់ឧបករណ៍ និងសេវាកម្មឌីជីថលរបស់ប្រព័ន្ធគាំពារសង្គម | ការលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់ប្រជាជនអំពីសេវាឌីជីថល នឹងត្រូវបានធ្វើឡើង។ | ២០២៥ - ២០២៦ |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | បង្គោលចរ | ឆ្នាំសម្រាប់ការអនុវត្ត |
|---|---|---|---|
| ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធព័ត៌មានវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល | **សកម្មភាពអាទិភាពទី១**<br>ធ្វើការវិភាគអំពីភាពខ្វះចន្លោះ និងកំណត់អាទិភាពនៃប្រព័ន្ធព័ត៌មានវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល | ការវិភាគស៊ីជម្រៅលើស្ថានភាពឌីជីថលរបស់តួអង្គគាំពារសង្គមនីមួយៗលើប្រព័ន្ធព័ត៌មានវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលមានស្រាប់ នឹងត្រូវធ្វើឡើង។ | ២០២៥<br>-<br>២០២៦ |
| | **សកម្មភាពអាទិភាពទី២**<br>អភិវឌ្ឍផែនការវិនិយោគសម្រាប់ការកែលម្អជាអាទិភាព | តាមរយៈលទ្ធផលនៃការវិភាគ, ផែនការអភិវឌ្ឍន៍ និងការវិនិយោគសម្រាប់ការធ្វើឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតនៃដំណើរការពង្រឹងប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល នឹងត្រូវបានអភិវឌ្ឍឡើង។ | ២០២៥<br>-<br>២០២៦ |
| | **សកម្មភាពអាទិភាពទី៣**<br>អភិវឌ្ឍផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT | ផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT ត្រូវបានគេមើលឃើញថាមានគុណសម្បត្តិដូចខាងក្រោម៖<br>• ធ្វើឱ្យការចែករំលែកទិន្នន័យផ្ទៃក្នុង និងរវាងតួអង្គគាំពារសង្គមទាំងអស់ឱ្យកាន់តែប្រសើរឡើង ដោយប្រើប្រាស់ CamDx ជាថ្នាលផ្លាស់ប្តូរទិន្នន័យរួម, ដែលនឹងរួមចំណែកក្នុងការពង្រឹងគោលការណ៍បញ្ចូលទិន្នន័យតែមួយដង (Only-Once Principle);<br>• ឧបករណ៍ឌីជីថលជាមធ្យោបាយក្នុងការផ្តល់សេវារហ័ស, ងាយស្រួល, និងល្អសម្រាប់អត្ថគាហក ឬអ្នកទទួលផល;<br>• ដំណើរការការងារដោយស្វ័យប្រវត្តិ នឹងជួយកាត់បន្ថយបន្ទុកការងារសម្រាប់ប្រតិបត្តិករគាំពារសង្គម; | ២០២៥<br>-<br>២០២៩ |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | បទដ្ឋានចរ | ឆ្នាំសម្រាប់ការអនុវត្ត |
|---|---|---|---|
| ការធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធព័ត៌មានវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល | **សកម្មភាពអាទិភាពទី៣**<br>អភិវឌ្ឍផែនការអភិវឌ្ឍ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធ ICT | • ទិសដៅអភិវឌ្ឍន៍ គឺឆ្ពោះទៅរកថ្នាលគាំពារសង្គមឌីជីថល និងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម ដែលមានភាពសុខដុម និងអាចធ្វើអន្តរប្រតិបត្តិការរវាងគ្នានឹងគ្នាបាន;<br>• ធ្វើឱ្យប្រសើរឡើងនូវការកំណត់អត្តសញ្ញាណប្រជាជនគោលដៅ និងអត្តគាហក ឬអ្នកទទួលផល; និង<br>• ពង្រឹងមុខងាររក្សាទុកទិន្នន័យបម្រុង នៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល។ | ២០២៥<br>-<br>២០២៩ |
| | **សកម្មភាពអាទិភាពទី៤**<br>ការកែលម្អការចុះបញ្ជីក្នុងកម្មវិធីជំនួយសង្គម ឬរបបសន្តិសុខសង្គមនានា។ | គម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ត្រូវបានអនុវត្ត ដោយដាក់ឱ្យដំណើរការនូវមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម និងថ្នាលគាំពារសង្គមឌីជីថល ដែលមានការចូលរួមដោយប្រតិបត្តិករគាំពារសង្គមទាំងអស់។ | ២០២៥<br>-<br>២០២៩ |
| ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការសម្របសម្រួលភាគីពាក់ព័ន្ធនៃកិច្ចខិតខំប្រឹងប្រែងបរិវត្តកម្មឌីជីថល | **សកម្មភាពអាទិភាពទី១**<br>អភិវឌ្ឍយន្តការប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងតួអង្គគាំពារសង្គមនានា | ការប្រជុំជាទៀងទាត់ក្នុងចំណោមតួអង្គគាំពារសង្គមទាំងអស់នឹងត្រូវធ្វើឡើង។ ដៃគូអភិវឌ្ឍន៍អាចរួមចំណែកយ៉ាងសកម្មក្នុងការពិភាក្សាជាយុទ្ធសាស្ត្រ<br>និងបច្ចេកទេស។ | ២០២៥<br>-<br>២០២៦ |
| | **សកម្មភាពអាទិភាពទី២**<br>បង្កើតបណ្តាញផ្លាស់ប្តូរព័ត៌មានក្រៅផ្លូវការសម្រាប់ប្រតិបត្តិករនៃប្រព័ន្ធគាំពារសង្គមទាំងអស់ | ថ្នាលផ្លាស់ប្តូរព័ត៌មាននឹងត្រូវអភិវឌ្ឍឡើងសម្រាប់ផ្តល់ព័ត៌មានអំពីគំនិតផ្តួចផ្តើមឌីជីថលដែលបាន និងកំពុងតែអនុវត្តពីគ្រប់តួអង្គពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល,<br>ដៃគូអភិវឌ្ឍន៍, និងវិស័យឯកជនដែលទាក់ទងទៅនឹងកិច្ចគាំពារសង្គមកម្ពុជា។ | ២០២៥<br>-<br>២០២៩ |

# ឧបសម្ព័ន្ធ២៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៤៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញសេចក្តីសម្រេចលេខ ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## **សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារបច្ចេកទេសទទួលបន្ទុកធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម មានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ចន ណារិទ្ធ** | អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | ប្រធាន |
| ២. | ឯកឧត្តម **គង់ ម៉ារី** | ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកក្រុមការងាររៀបចំសេចក្តីព្រាងក្របខណ្ឌគោល-នយោបាយរដ្ឋាភិបាលឌីជីថល | អនុប្រធាន |
| ៣. | លោក **យិន ម៉ាលីណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. | ឯកឧត្តម **សុខ សំអាង** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល | សមាជិក |
| ៥. | ឯកឧត្តម **អ៊ុក ចណ្ណាឌី** | ទីប្រឹក្សា និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦. | លោក **ប្រាក់ ម៉ូច** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៧. | លោក **យោគ សាមឌី** | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ៨. | លោក **ឡៅ វ៉េង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩. | លោក **ម៉ុល ចាន់ដារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០. | លោក **នៅ សុផន** | ប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១. | លោក **កែវ អ៊ុលី** | ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ | សមាជិក |
| ១២. | លោក **តាំង ខួនលី** | ប្រធានលេខាធិការដ្ឋានមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” តំណាងមជ្ឈមណ្ឌលស្រាវជ្រាវធុរកិច្ចឌីជីថល | សមាជិក |
| ១៣. | លោកស្រី **កើត ពេជ្រចិន្តា** | នាយកទីភ្នាក់ងារបញ្ជាក់ចំណាយសុខាភិបាល | សមាជិក |
| ១៤. | លោក **ហ៊ិញ ឫទ្ធីពល** | អនុប្រធាននាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ១៥. លោក **ជី សួរ** | ប្រធានការិយាល័យព័ត៌មានវិទ្យានៃបេឡាជាតិរបប-សន្តិសុខសង្គម | សមាជិក |
| ១៦. លោកស្រី **ទ៉ាន់ អឌីត្តា** | ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម | លេខាធិការ |

ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម អាចមានសមាសភាពបន្ថែមតាមការចាំបាច់។

**ប្រការ ២.-**

ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សិក្សាលើទិដ្ឋភាពទូទៅ និងបញ្ហាប្រឈមនានានៃប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងការងារគាំពារសង្គមដែលបាន និងកំពុងដំណើរការ
- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពលើលទ្ធភាពនៃការតភ្ជាប់ ឬធ្វើសមាហរណកម្មប្រព័ន្ធចុះបញ្ជី ឬប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម ដែលមានស្រោប់ក្នុងកម្រិតមិនប៉ះពាល់ដល់ព័ត៌មានឯកជនភាពបុគ្គល
- ផ្តល់យោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នឯកជនលើការងារពាក់ព័ន្ធនឹងការរៀបចំ ដំឡើង កែសម្រួលប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធព័ត៌មានវិទ្យាដែលពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម ដើម្បីឱ្យអាចធ្វើអន្តរប្រតិបត្តិការជាមួយគ្នាបាន
- រាយការណ៍ជាប្រចាំជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គមស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធព័ត៌មានវិទ្យាដែលពាក់ព័ន្ធនឹងការងារគាំពារសង្គម
- បំពេញការងារផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាជាតិគាំពារសង្គម។

**ប្រការ ៣.-**

សមាសភាពនៃក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គម ដូចមានចែងក្នុង ប្រការ១ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬចាត់តំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេស។

ក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និងគ្រប់គ្រងទិន្នន័យគាំពារសង្គមអាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍន៍ និងតំណាងវិស័យឯកជន ដើម្បីពិភាក្សាការងារតាមការចាំបាច់។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុង ប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំជូតទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ